# បរិការណ៍នៃការអភិរក្សនៅប្រទេសកម្ពុជា និងបញ្ហាប្រឈម





WWF

ANGKOR CENTRE FOR CONSERVATION OF BIODIVERSITY
ACCB
A KINGDOM OF CAMBODIA/GOETZ-PROJECT

ALLWETTERZOO MÜNSTER

WTG
Welttierschutz-gesellschaft e.V.

# បរិការណ៍នៃការអភិរក្សនៅប្រទេសកម្ពុជានិងបញ្ហាប្រឈម

## មគ្គុទ្ទេសក៍សម្រាប់ព្រះសង្ឃពុទ្ធសាសនា នៅប្រទេសកម្ពុជា


សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការ WWF និង អង្គការ WTG
ដែលបានចូលរួមឧបត្ថម្ភថវិកាដើម្បីបោះពុម្ពសៀវភៅនេះឡើង



**សៀវភៅនេះរៀបរៀងឡើងដោយៈ**

ជិម សុភាព
គ្រីសតែល ហ្គ្រិហ្វីយ៉ូន
ជូលៀ ស្តេនខាត់
វ៉ាន់ សុជា
តង ស្រីលាភ





រក្សាសិទ្ធិដោយមជ្ឈមណ្ឌលអង្គរសម្រាប់ការអភិរក្សជីវៈចម្រុះ និង អង្គការ WWF © ឆ្នាំ២០២១

# មាតិកា


- **សេចក្តីផ្តើម**
  - មជ្ឈមណ្ឌលអង្គរសម្រាប់ការអភិរក្សជីវៈចម្រុះ (ACCB)......១
  - ហេតុអ្វីបានជា ACCB សង្គ្រោះសត្វព្រៃ......២
- បរិស្ថាន......៣
  - ហេតុអ្វីបានជាពួកយើងមានភារៈចាំបាច់ក្នុងការថែរក្សានិងការពារបរិស្ថាន?......៤
- ជីវៈចម្រុះ......៥
  - ហេតុអ្វីបានជាជីវៈចម្រុះមានសារៈសំខាន់?......៧
- ឋានប្រព័ន្ធ......៨
  - ហេតុអ្វីបានជាឋានប្រព័ន្ធមានសារៈសំខាន់ចំពោះការរស់នៅរបស់មនុស្ស?......៩
  - ឋានប្រព័ន្ធសំខាន់ៗនៅប្រទេសកម្ពុជា......១០
  - ឋានប្រព័ន្ធបឹងទន្លេសាប......១១

# មាតិកា


- ឋានប្រព័ន្ធតំបន់ឆ្នេរនិងសមុទ្រ..........១៣
- ឋានប្រព័ន្ធព្រៃរងទឹកភ្លៀងជួរភ្នំក្រវាញ..........១៤

- ការអភិរក្ស..........១៥
  - ហេតុអ្វីបានការអភិរក្សមានសារៈសំខាន់ចំពោះការរស់នៅរបស់មនុស្ស?..........១៦
- ទំនាក់ទំនងរវាងមនុស្សជាតិនិងធម្មជាតិ..........១៧
  - ជំនឿអរូបិយ ឬជំនឿលើដួងព្រលឹងតាមទំនៀមទំលាប់បុរាណក្នុងសង្គមខ្មែរ..........១៨
  - ហេតុអ្វីបានជាបរិស្ថានមានសារៈសំខាន់ចំពោះជំនឿនិងគុណតម្លៃរបស់មនុស្ស?..........១៩
- លក្ខណៈពិសេសនៃធនធានធម្មជាតិនិងជីវៈចម្រុះរបស់ប្រទេសកម្ពុជា..........២០
- ការគំរាមកំហែងចំពោះការអភិរក្សនៅលើពិភពលោក: ការប្រែប្រួលអាកាសធាតុ..........២២
- ការគំរាមកំហែងចំពោះការអភិរក្សនៅប្រទេសកម្ពុជា..........២៤

# មាតិកា


- ការកាប់បំផ្លាញព្រៃឈើនិងការបំផ្លិចបំផ្លាញទីជម្រក.......................................២៥
- ការទាក់ចាប់សត្វ ការបរបាញ់សត្វនិងការជួញដូរសត្វព្រៃ.......................................២៦
- បទល្មើសសត្វព្រៃដែលមានការរៀបចំជាប្រព័ន្ធ.......................................២៨
- ការបំពុលដោយប្លាស្ទិក.......................................២៩
- ការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតនិងសារធាតុពុលផ្សេងទៀតមិនបានត្រឹមត្រូវ.......................................៣១
- ប្រភេទរាតត្បាត.......................................៣២
- តើអ្នកអាចធ្វើអ្វីបានខ្លះដើម្បីជួយដល់ការអភិរក្សនៅក្នុងតំបន់ ?.......................................៣៣
- សូមប្រើប្រាស់ធនធានធម្មជាតិឱ្យមាននិរន្តរភាពជាងមុន.......................................៣៤
- ប្រើប្រាស់រុក្ខជាតិដែលផ្តល់ប្រភពប្រូតេអ៊ីនក្នុងរបបអាហាររបស់អ្នកនិងធ្វើជាឱសថបុរាណ។ ប្រើប្រាស់ឱសថបុរាណនិងប្រភេទចំណីអាហារដែលមាននិរន្តរភាព.......................................៣៥

# មាតិកា


- កាត់បន្ថយការជួញដូរសត្វព្រៃតាមរយៈការលើកម្ពស់ការយល់ដឹង.....................................................................៣៦
- សូមកាត់បន្ថយការប្រើប្រាស់សម្ភារៈប្លាស្ទិកដែលប្រើតែមួយដងបោះចោល...................................................៣៧
- សូមប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតឱ្យបានត្រឹមត្រូវ..........................................................................................៣៨

- **ច្បាប់និងបទបញ្ញាតិផ្សេងៗ**
  - ការអភិរក្សសត្វព្រៃ( ជំពូក ទី១០ )....................................................................................................................៣៩
  - ការការពារនិងការអភិរក្សជលផល ( ជំពូក ទី៥ )...............................................................................................៤១
- **មគ្គុទ្ទេសក៍ឆ្ពោះទៅស្គាល់ប្រភេទសត្វសំខាន់ៗដែលព្រះសង្ឃរមែងជួបប្រទះ**

១- ស្វាក្ដាម Common Long-tailed Macaque *(Macaca fascicularis)*.......................................................៤២

២- ស្វាត្រោស Northern Pig-tailed Macaque *(Macaca leonina)*.............................................................៤៣

៣- ទោចម្កុដ Pileated Gibbon *(Hylobates pileatus)*..................................................................................៤៤

៤- ព្រៀប្រផេះ Bengal Slow Loris *(Nycticebus bengalensis)*.............................................................................៤៥

# មាតិកា

៥- រញ៉េភ្លើង Pygmy Slow Loris *(Nycticebus pygmaeus)*..........៤៦
៦- ស្វាព្រាម Indochinese Silvered Langur *(Trachypithecus germaini)*..........៤៧
៧- ឆ្មាដាវ Leopard Cat *(Prionailurus bengalensis)*..........៤៨
៨- សំពោចក្រអូប Common Palm Civet *(Paradoxurus hermaphroditus)*..........៤៩
៩- ស្កាតូច Javan Mongoose *(Herpestes javanicus)*..........៥០
១០- ខ្លាឃ្មុំតូច Sun Bear *(Helarctos malayanus)*..........៥១
១១- ជ្រូកព្រៃ Wild Boar *(Sus scrofa)*..........៥២
១២- ទន្សោង Banteng *(Bos javanicus)*..........៥៣
១៣- ខ្ទីង Gaur *(Bos gaurus)*..........៥៤
១៤- ឈ្លូស Northern Red Muntjac *(Muntiacus vaginalis)*..........៥៥
១៥- ប្រើស Sambar Deer *(Rusa unicolor)*..........៥៦
១៦- ក្តាន់ Hog Deer *(Axis porcinus)*..........៥៧

# មាតិកា

១៧- ក្តាន់ញ៉ៀងតូច ឬផ្ទងតូច Lesser Mousedeer *(Tragulus kanchil)*....................................៥៨
១៨- រមាំង Eld's Deer *(Rucervus eldii)*....................................................................................៥៩
១៩- ខ្លាធំ ឬខ្លាដំបង Tiger *(Panthera tigris)*.............................................................................៦០
២០- ពង្រូល Sunda Pangolin *(Manis javanica)*.........................................................................៦១
២១- ដំរីអាស៊ី Asian Elephant *(Elephas maximus)*....................................................................៦២
២២- ផ្សោតក្បាលត្រឡោក Irrawaddy Dolphin *(Orcaella brevirostris)*..........................................៦៣
២៣- អណ្តើកបិទមុខស្នូកខ្មៅ Southeast Asian Box Turtle *(Cuora amboinensis)*..........................៦៤
២៤- អណ្តើកព្រេច Elongated Tortoise *(Indotestudo elongata)*....................................................៦៥
២៥- អណ្តើកស្រែ Mekong Snail-eating Turtle *(Malayemys subtrijuga)*......................................៦៦
២៦- អណ្តើកសោម Giant Asian Pond Turtle *(Heosemys grandis)*................................................៦៧
២៧- អណ្តើកសង្កល់ ឬអណ្តើកក្របីក្បាលលឿង Yellow-headed Temple Turtle *(Heosemys annandalii)*.........៦៨
២៨- អណ្តើកហ្លួង ឬអណ្តើកសរសៃ Southern River Terrapin *(Batagur affinis)*................................៦៩

# មាតិកា


២៩- កន្ធាយក្បាលកង្កែប ឬល្មេច Asian Giant Softshell Turtle *(Pelochelys cantorii)*........................................៧០
៣០- កន្ធាយអាស៊ី Asiatic Softshell Turtle *(Amyda cartilaginea)*..............................................................៧១
៣១- ពស់ថ្លាន់តូច ឬពោះថ្លាន់ក្បាលខ្មៅ Burmese Python *(Python bivittatus)*.............................................៧២
៣២- ពស់ថ្លាន់ធំ ឬពោះថ្លាន់ក្បាលលឿង Reticulated Python *(Malayopython reticulatus)*...............................៧៣
៣៣- អន្សង Common Water Monitor *(Varanus salvator)*...............................................................................៧៤
៣៤- ត្រកួត Clouded Monitor *(Varanus bengalensis)*.....................................................................................៧៥
៣៥- ត្រដក់ធំ Greater Adjutant *(Leptoptilos dubius)*.....................................................................................៧៦
៣៦- ត្រដក់តូច Lesser Adjutant *(Leptoptilos javanicus)*.................................................................................៧៧
៣៧- ត្រុំ កុកពាក់អំបោះ ឬសត្វកស Asian Woollyneck *(Ciconia episcopus)*.....................................................៧៨
៣៨- ក្ងោក Green Peafowl *(Pavo muticus)*........................................................................................................៧៩
៣៩- ខ្លែងឆាបលឿងក្រមៅ Brahminy Kite *(Haliastur indus)*...............................................................................៨០

# មាតិកា

៤០- អកពស់ព្រៃ Crested Serpent-eagle (*Spilornis cheela*)....................................................៨១
៤១- អកព្រៃច្រើនពណ៌ Changeable Hawk-eagle (*Nisaetus cirrhatus*)...........................................៨២
៤២- ខ្លែងស្រាក Common Barn-owl (*Tyto alba*).................................................................................៨៣
៤៣- សេកសក Red-breasted Parakeet (*Psittacula alexandri*).........................................................៨៤
៤៤- សេកសោម Alexandrine Parakeet (*Palaeornis eupatria*)..........................................................៨៥
៤៥- ចាបបចង្រុង់ Scaly-breasted Munia (*Lonchura punctulata*)...................................................៨៦
៤៦- ត្រចៀកកាំ Barn Swallow (*Hirundo rustica*)...............................................................................៨៧
៤៧- សារិកាកែវវង Common Hill Myna (*Gracula religiosa*).....................................................................៨៨
៤៨- ត្រយងយក្ស Giant Ibis (*Thaumatibis gigantea*)............................................................................៨៩
៤៩- ត្រយងចង្កំកស White-shouldered Ibis (*Pseudibis davisoni*)..................................................៩០
៥០- ត្មាតភ្លើង Red-headed Vulture (*Sarcogyps calvus*)....................................................................៩១

# មាតិកា


៩១- ត្មាតផេះ White-rumped Vulture *(Gyps bengalensis)*......................................................៩២
៩២- ត្មាតត្នោត Slender-billed Vulture *(Gyps tenuirostris)*......................................................៩៣
៩៣- ក្រៀល Sarus Crane *(Grus antigone)*......................................................៩៤
៩៤- ខ្សឹប ឬទ្រមាក់អណ្ដើក Bengal Florican *(Houbaropsis bengalensis)*......................................................៩៥
៩៥- រំពេទន្លេ River Tern *(Sterna aurantia)*......................................................៩៦
៩៦- បបែលទឹកសាប Giant Freshwater Ray *(Urogymnus polylepis)*......................................................៩៧
៩៧- ត្រីត្រសក់ Seven-striped Barb *(Probarbus jullieni)*......................................................៩៨
៩៨- ត្រីគល់រាំង ឬត្រីក្បាលឡាន Giant Barb *(Catlocarpio siamensis)*......................................................៩៩
៩៩- ត្រីរាជ Mekong Giant Catfish *(Pangasianodon gigas)*......................................................១០០

# សេចក្តីផ្តើម៖
# មជ្ឈមណ្ឌលអង្គរសម្រាប់ការអភិរក្សជីវៈចម្រុះ (ACCB)

មជ្ឈមណ្ឌលអង្គរសម្រាប់ការអភិរក្សជីវៈចម្រុះ (ACCB) គឺជាមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃនិងអភិរក្សជីវៈចម្រុះមួយដែលមានទីតាំងស្ថិតនៅជើងភ្នំក្បាលស្ពាន (ឧទ្យានជាតិភ្នំគូលែន)។ ACCB មានគោលបំណងសំខាន់ដើម្បីចូលរួមចំណែកដល់ការសង្គ្រោះសត្វព្រៃនិងការអភិរក្សជីវៈចម្រុះនៅប្រទេសកម្ពុជា។ គំនិតផ្តួចផ្តើមបង្កើតមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃនៅក្បែរឧទ្យានជាតិអង្គរមានប្រភពដំបូងបង្អស់មកពីជីវវិទូជនជាតិខ្មែរមួយរូបដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញលើឆាកអន្តរជាតិគឺលោក សំ វាសនា។ ដោយមានការឧបត្ថម្ភគាំទ្រពីសួនសត្វ អាល់វិតធឿស្សូម៉ឺនស្ទឿ (Allwetterzoo Munster) និងសួនសត្វ ហ្សេតជីអេភី ZGAP (Zoological Society for the Conservation of Species and Populations) នៅប្រទេសអាល្លឺម៉ង់ ទើបមជ្ឈមណ្ឌលអង្គរសម្រាប់ការអភិរក្សជីវៈចម្រុះអាចចាប់ផ្តើមដំណើរការណ៍មជ្ឈមណ្ឌលរបស់ខ្លួនបានចាប់តាំងពីឆ្នាំ២០០៣ មក។

# ហេតុអ្វីបានជា ACCB សង្គ្រោះសត្វព្រៃ

- សត្វមួយចំនួនដែលត្រូវបានជួយសង្គ្រោះហើយបានរក្សាទុកនៅ ACCB ក្រោមហេតុផលសំខាន់ៗបីយ៉ាងគឺ៖
  - ដើម្បីស្តារនីតិសម្បទាមុនពេលលែងត្រឡប់ទៅក្នុងជម្រកធម្មជាតិវិញ
  - សត្វព្រៃដែលសង្គ្រោះបានហើយ តែមិនអាចលែងបាន
  - ប្រភេទសត្វព្រៃដែលចាំបាច់ត្រូវតែអភិរក្ស









# បរិស្ថាន

- បរិស្ថានមានន័យថាយើងទាំងអស់គ្នានិងអ្វីៗដែលនៅជុំវិញខ្លួនយើង មានទាំងភាវៈមានជីវិតនិងភាវៈគ្មានជីវិតផងដែរ។
- ភាវៈមានជីវិតនិងភាវៈគ្មានជីវិតទាំងនោះ ដែលមានវត្តមាននៅលើផែនដីនេះមានទំនាក់ទំនងនឹងគ្នាហើយជះឥទ្ធិពលដល់គ្នាទៅវិញទៅមក។
- **ផ្នែកទាំង៣ របស់បរិស្ថានមាន៖**
  - បរិស្ថានធម្មជាតិ
  - បរិស្ថានសង្គម-វប្បធម៌
  - បរិស្ថានមនុស្ស



# ហេតុអ្វីបានជាពួកយើងមានភារៈចាំបាច់ក្នុងការថែរក្សានិងការពារបរិស្ថាន?

បរិស្ថានគឺជាលំនៅដ្ឋានរបស់យើង ហើយវាជួយដល់ឋានប្រព័ន្ធរបស់យើងឱ្យលូតលាស់និងរីកចម្រើន។ បើគ្មានការការពារនិងថែរក្សាបរិស្ថានរបស់យើងទេ វានឹងធ្វើឱ្យមានគ្រោះថ្នាក់ដល់ជីវិតយ៉ាងច្រើនដូចជាសត្វ រុក្ខជាតិនិងដំណាំផ្សេងៗ ព្រមទាំងជីវិតរបស់យើងផ្ទាល់។ គ្រប់ឋានប្រព័ន្ធទាំងអស់ដែលកកើតនៅក្នុងបរិស្ថានរបស់យើង គឺមានទំនាក់ទំនងនឹងគ្នាយ៉ាងជិតស្និទ្ធ។

- **ជីវៈចម្រុះ**
  - ហេតុអ្វីបានជាជីវៈចម្រុះមានសារៈសំខាន់?
- **ឋានប្រព័ន្ធ**
  - ហេតុអ្វីបានជាឋានប្រព័ន្ធមានសារៈសំខាន់ចំពោះការរស់នៅរបស់មនុស្ស?
  - ឋានប្រព័ន្ធសំខាន់ៗនៅប្រទេសកម្ពុជា
- **ការអភិរក្ស**
  - ហេតុអ្វីបានការអភិរក្សមានសារៈសំខាន់ចំពោះការរស់នៅរបស់មនុស្ស?
- **ទំនាក់ទំនងរវាងមនុស្សជាតិនិងធម្មជាតិ**
  - ជំនឿអរូបិយ ឬជំនឿលើដួងព្រលឹងតាមទំនៀមទំលាប់បុរាណនៅក្នុងសង្គមខ្មែរ
  - ហេតុអ្វីបានជាបរិស្ថានមានសារៈសំខាន់ចំពោះជំនឿ និងគុណតម្លៃរបស់មនុស្ស?



# ជីវៈចម្រុះ

ជីវៈ + ចម្រុះ

ជីវៈ = ជីវិត

ចម្រុះ = ដែលលាយឡំគ្នា

ជីវៈចម្រុះមានន័យថាប្រភេទខុសៗគ្នាជាច្រើននៃជីវិតដែលរស់នៅក្នុងតំបន់ដូចគ្នា ឬផ្សេងៗគ្នានៅលើផែនដីដែលមានអន្តរអំពើជាមួយគ្នាទៅវិញទៅមក។

ប្រភេទនីមួយៗមានតួនាទីសំខាន់រៀងៗខ្លួននៅក្នុងឋានបព័ន្ធ។

# ហេតុអ្វីបានជាជីវៈចម្រុះមានសារៈសំខាន់?



គ្រប់ផ្នែកទាំងអស់នៃជីវៈចម្រុះនិងគ្រប់ឋានប្រព័ន្ធនៅទូទាំងពិភពលោកគឺមានសារៈសំខាន់ខ្លាំងណាស់ដោយសារពួកវាគឺជាផ្នែកមួយនៃបណ្ដាញទំនាក់ទំនងគ្នាទៅវិញទៅមកយ៉ាងធំជាសាកល។

នេះបានឆ្លុះបញ្ចាំងពីទ្រឹស្តីក្នុងព្រះពុទ្ធសាសនាដែលបានចែងថា *"អ្វីៗទាំងអស់គឺជាធាតុផ្សំនិងអាស្រ័យគ្នាទៅវិញទៅមក។ លើសពីនេះទៅទៀតសត្វគឺជាភាវៈមានជីវិតដែលអាចមានអារម្មណ៍ភ័យខ្លាចនិងឈឺចាប់ដូចជាមនុស្សយើងដែរ ដូច្នេះហើយពួកវាសមនឹងទទួលបាននូវសេចក្តីមេត្តា ករុណាពីពួកយើង"។*

មនុស្សក៏ជាផ្នែកមួយនៃជីវៈចម្រុះផងដែរ។

# ឋានប្រព័ន្ធ ឬប្រព័ន្ធអេកូឡូស៊ី

## ឋាន + ប្រព័ន្ធ

**ឋាន= បរិស្ថាន** | **ប្រព័ន្ធ= អន្តរកម្ម**

ឋានប្រព័ន្ធ ឬប្រព័ន្ធអេកូឡូស៊ីគឺជាសហគមន៍ផ្សេងៗគ្នា ដែលមានអន្តរកម្មជាមួយគ្នា និងជាមួយបរិស្ថានគ្មានជីវិតនៅក្នុងតំបន់ណាមួយ។ សហគមន៍កើតឡើងពី បណ្តាភាវៈរស់ទាំងឡាយនៃប្រភេទនានាដែលមាននៅក្នុងតំបន់ណាមួយ។

# ហេតុអ្វីបានជាប្រព័ន្ធមានសារៈសំខាន់ចំពោះការរស់នៅរបស់មនុស្ស?

- ឋានប្រព័ន្ធរួមមានខ្សែអាហារនិងបណ្ដាញអាហារ (អន្តរកម្មរវាងសត្វរំពានិងរំពា) ក៏ដូចជាទីជម្រកសត្វ (កន្លែងដែលសត្វរកចំណីអាហារ ទឹក ជម្រក ទីជ្លា និងការបន្តពូជ) ព្រមទាំងទេសភាពនានាមានដូចជាផ្ទៃដី បរិយាកាស និងរយៈកំពស់ផងដែរ។
  - សត្វឃ្មុំធ្វើដំណើរលំអងដល់ព្រៃឈើនិងដំណាំហូបផ្លែផ្សេងៗពេលដែលពួកវាយកទឹកដមផ្កាដើម្បីផលិតជាទឹកឃ្មុំ។
  - សត្វត្មាតគឺជាប្រភេទបក្សីធំដែលស៊ីសាកសពសត្វព្រៃនិងសត្វស្រុក។
  - ជីវិតទាំងអស់នៅលើភពផែនដីពឹងផ្អែកទាំងស្រុងទៅលើអត្ថិភាពរបស់ដើមឈើនិងព្រៃឈើ។



# ហេតុអ្វីបានជាឋានប្រព័ន្ធមានសារៈសំខាន់ចំពោះការរស់នៅរបស់មនុស្ស?

- សេវាកម្មឋានប្រព័ន្ធគឺជាអត្ថប្រយោជន៍ជាវិជ្ជមានទាំងឡាយ ដែលសត្វព្រៃ ឬឋានប្រព័ន្ធ ផ្តល់ឱ្យដល់មនុស្ស (ដោយផ្ទាល់ ឬដោយប្រយោល)។
- មានសេវាកម្មឋានប្រព័ន្ធធំៗចំនួនបួន(៤) ប្រភេទគឺ:
  - សេវាកម្មផ្តល់និងចែកចាយ: ម្ហូបអាហារ សម្ភារៈប្រើប្រាស់ផ្សេងៗនិងប្រភពថាមពល
  - សេវាកម្មនិយតកម្ម: ធ្វើឱ្យមានលំនឹងអាកាសធាតុនិងការពារជំងឺ
  - សេវាកម្មវប្បធម៌: ទាក់ទងទៅនឹងវប្បធម៌និងជំនឿអរូបិយផ្សេងៗដែលជាតម្រូវការរបស់មនុស្ស
  - សេវាកម្មទ្រទ្រង់: វដ្តៈនៃសារធាតុចិញ្ចឹមផ្សេងៗនិងការផលិតនូវអុកស៊ីសែន



# ឋានប្រព័ន្ធសំខាន់ៗនៅប្រទេសកម្ពុជា



# ឋានប្រព័ន្ធបឹងទន្លេសាប

- បឹងទន្លេសាបជាឋានប្រព័ន្ធដែលមានសារៈសំខាន់បំផុតរបស់ប្រទេសកម្ពុជាៈ
  - មានប្រព័ន្ធខ្សែទឹកលក្ខណៈពិសេសអស្ចារ្យៈ លំហូរបញ្ច្រាសទិសជារៀងរាល់ឆ្នាំ (ទឹកហូរចូលនៅរដូវវស្សានិងហូរចេញនៅរដូវប្រាំង)
  - ជាបឹងទឹកសាបធំជាងគេនៅអាស៊ីអាគ្នេយ៍ៈ មានទំហំចន្លោះពី២៥០០ ទៅ ៣០០០គ.ម ក្រឡា(រដូវប្រាំង)។ ចន្លោះ ពី៩០០០ ទៅ ១៤០០០គ.ម ក្រឡា(រដូវវស្សា)
  - មានព្រៃលិចទឹកនៅសេសសល់ធំជាងគេបំផុតនៅក្នុងតំបន់ៈ(៣០០០០០ ហ.ត)
  - ផ្តល់ទិន្នផលត្រីទឹកសាបច្រើនជាងគេបំផុតនៅកម្ពុជានិងជាបឹងមួយក្នុងចំណោមបឹងដែលផ្តល់ទិន្នផលត្រីខ្ពស់បំផុតនៅលើពិភពលោក
  - មានហ្វូងសត្វស្លាបទឹកច្រើនជាងគេនៅអាស៊ីអាគ្នេយ៍និងជាជម្រកពងកូនដ៏មានសារៈសំខាន់សម្រាប់ប្រភេទសត្វទឹកដ៏កម្រទាំងនោះ
  - ប្រភេទមានដោយតំបន់ៈ ពស់ផ្អក ឬប្រលឹតដូង (Tonlé Sap Water Snake)
  - ប្រជាជនកម្ពុជាជាង ៣ លាននាក់ អាស្រ័យផលដោយផ្ទាល់ពីធនធានធម្មជាតិក្នុងបឹងទន្លេសាប






# ឋានប្រព័ន្ធបឹងទន្លេសាប







# ឋានប្រព័ន្ធតំបន់ឆ្នេរនិងសមុទ្រ

- ព្រៃកោងកាងមានតួនាទីយ៉ាងសំខាន់សម្រាប់ការរស់រានមានជីវិតរបស់មច្ឆជាតិជាច្រើនប្រភេទនិងភាវៈមានជីវិតនៅក្នុងសមុទ្រជាច្រើនផ្សេងទៀត ហើយផ្តល់ទីជម្រកសម្រាប់ពងកូន ឬជាទីជម្រកសម្រាប់ពូជត្រីសំខាន់ៗជាច្រើនប្រភេទ
- ស្មៅបាតសមុទ្រដែលដុះតាមឆ្នេររាក់ៗជួយការពារតំបន់ឆ្នេរ ហើយផ្តល់ជាទីជម្រកដល់កូនត្រីតូចៗនិងមានមុខងារថែទាំដល់ពូជមច្ឆាជាច្រើនប្រភេទ
- ផ្កាថ្មប៉ប្រះទឹកមានសារៈសំខាន់ណាស់ចំពោះឋានប្រព័ន្ធតំបន់ឆ្នេរ វាផ្តល់ជូនសហគមន៍មូលដ្ឋាននូវសេវាកម្មផ្នែកសេដ្ឋកិច្ចនិងសង្គម ព្រមទាំងទ្រព្យដ៏មានតម្លៃជាច្រើនផ្សេងទៀត





# ឋានប្រព័ន្ធព្រៃរងទឹកភ្លៀងជួរភ្នំក្រវាញ

- ជាតំបន់ដ៏ធំទូលាយ ប្រមូលផ្តុំទៅដោយឋានប្រព័ន្ធទាំង១៦ ដែលចាក់ស្រេះគ្នាជាអន្តរកម្ម មានចាប់ពីព្រៃស្រោង រហូតដល់វាលទំនាបដីល្បាប់និងព្រៃកោងកាង។
- ជាតំបន់ជីវៈចម្រុះដ៏មានសារៈសំខាន់ដែលទទួលស្គាល់ជាលក្ខណៈអន្តរជាតិ និងជាតំបន់ជីវៈចម្រុះសំខាន់មួយនៅក្នុងតំបន់ឥណ្ឌូភូមា ដែលជាច្រកបៀងចុងក្រោយរបស់សត្វដំរីនិងជាទីជម្រកដ៏ធំរបស់ពួកសត្វរំពាជាច្រើនប្រភេទនៅក្នុងតំបន់។
- ជាជម្រកនៃពពួកថនិកសត្វធំៗយ៉ាងច្រើនស្ទើរតែគ្រប់ប្រភេទនិងប្រហែលជា ៥០% នៃប្រភេទសត្វស្លាប ប្រភេទល្មូន និងពួកថលជលិកទាំងអស់ដែលមានវត្តមាននៅកម្ពុជា។
- ប្រជាជនប្រហែលជា ១០០០០នាក់ អាស្រ័យផលពីព្រៃឈើនិងធនធានធម្មជាតិផ្សេងទៀតនៅក្នុងតំបន់ ដែលផ្តល់ជាសន្តិសុខស្បៀងនិងតម្រូវការផ្សេងៗទៀត (ដោយផ្ទាល់ ឬដោយប្រយោល)។





# ការអភិរក្ស

- ការអភិរក្សគឺសំដៅទៅលើសកម្មភាពទាំងឡាយណាដែលអនុវត្តឡើងក្នុងគោលបំណង៖
  - ដើម្បីការពារសត្វព្រៃនិងប្រភេទសត្វ
  - ដើម្បីថែរក្សាទីជម្រកនិងឋានប្រព័ន្ធ
  - ដើម្បីទប់ស្កាត់កុំឱ្យបាត់បង់ជីវៈចម្រុះ
- ដើម្បីការពារសត្វព្រៃបាន  វាជារឿងសំខាន់ដែលត្រូវស្វែងយល់អំពីអន្តរកម្មរវាងប្រភេទទាំងនោះនិងឋានប្រព័ន្ធរបស់វាហើយត្រូវស្វែងយល់ថាតើពួកវាទទួលរងនូវផលប៉ះពាល់យ៉ាងណាខ្លះពីឥទ្ធិពលរបស់បរិស្ថាននិងមនុស្ស។



# ហេតុអ្វីបានការអភិរក្សមានសារៈសំខាន់ចំពោះការរស់នៅរបស់មនុស្ស?

- ការអភិរក្សសត្វព្រៃគឺដើម្បីការពារខ្លួនអ្នកផ្ទាល់និងសហគមន៍របស់អ្នក
- ការអភិរក្សសត្វព្រៃនាំឱ្យមាននិរន្តរភាពចំណីអាហារ ទឹកស្អាតនិងខ្យល់បរិសុទ្ធ
- ការអភិរក្សសត្វព្រៃមានន័យថា ពួកយើងអាចប្រាកដថាក្មេងៗជំនាន់ក្រោយអាចរីករាយនឹងពិភពធម្មជាតិដ៏ស្រស់ស្អាតរបស់យើង ព្រមទាំងប្រភេទសត្វដ៏កម្រដែលរស់នៅទីនោះ
- ការអភិរក្សសត្វព្រៃ ជួយបង្កើនឱកាសការងារ មុខរបរចិញ្ចឹមជីវិតសម្រាប់សហគមន៍មូលដ្ឋាន (អនុផលព្រៃឈើនិងសេវាកម្មអេកូទេសចរណ៍ជាដើម)



# ទំនាក់ទំនងរវាងមនុស្សជាតិនិងធម្មជាតិ

ពេលបច្ចុប្បន្ននេះជម្រកសត្វព្រៃនៅប្រទេសកម្ពុជាទទួលរងនូវការគំរាមកំហែងកាន់តែខ្លាំងឡើងៗដោយសារការកាប់ឈើ ការទាក់ចាប់សត្វនិងការរានព្រៃយកដីសម្រាប់គម្រោងអភិវឌ្ឍសេដ្ឋកិច្ចមួយចំនួនមានដូចជា ការធ្វើកសិកម្មទ្រង់ទ្រាយធំ និងទំនប់វារីអគ្គីសនីខ្នាតធំ។



## រឿងសុវណ្ណសាមៈ

រឿងនិទាននេះបង្ហាញអំពីទំនាក់ទំនងរវាងមនុស្សជាតិនិងធម្មជាតិ។ សុវណ្ណសាមគឺជាក្មេងប្រុសម្នាក់រស់នៅក្នុងព្រៃភ្នំ។ រាល់ថ្ងៃគាត់ដងទឹកនិងរកម្ហូបអាហារនៅក្នុងព្រៃដើម្បីចិញ្ចឹមម្ដាយឪពុកពិការភ្នែករបស់គាត់។ គាត់ធំដឹងក្ដីមកក៏ស្គាល់និងទទួលបានក្ដីស្រលាញ់ពីម្រឹគីម្រឹគាទាំងពួង ហើយសត្វព្រៃទាំងពួងមិនខ្លាចគាត់ទេ។

# ជំនឿអរូបិយ ឬជំនឿលើដូងព្រលឹងតាមទំនៀមទំលាប់បុរាណក្នុងសង្គមខ្មែរ

- ជំនឿអរូបិយ ជឿថាអ្វីៗទាំងអស់មានដួងព្រលឹង។ វិញ្ញាណទាំងនោះរួមមាន ទន្លេ ភ្នំ ព្រៃឈើ ថ្ម ដើមឈើធំៗ ដុំថ្មដែលមានទម្រង់យ៉ាងចម្លែក ដំបូក ឈើដែលមានទម្រង់ដូចលឹង្គនិងវត្ថុផ្សេងៗជាច្រើនទៀត។
- ពាក្យថាអ្នកតា ត្រូវបានគេប្រើតំណាងឱ្យដួងព្រលឹងទាំងនោះ។
- ទន្លេនិងសមុទ្រដើរតួនាទីយ៉ាងសំខាន់តាមបែបបទនៃជំនឿក្នុងមូលដ្ឋាននិងជាអត្តសញ្ញាណវប្បធម៌។
- បឹងទន្លេសាប ទន្លេមេគង្គ និងតំបន់ជួរភ្នំក្រវាញ មានអ្នកតាសាកសិទ្ធិសំខាន់ៗមួយចំនួន។



# ហេតុអ្វីបានជាបរិស្ថានមានសារៈសំខាន់ចំពោះជំនឿនិងគុណតម្លៃរបស់មនុស្ស?

- ពិធីបុណ្យជាច្រើននៅប្រទេសកម្ពុជាមានប្រភពមកពីជំនឿនិងគុណតម្លៃតាមទំនៀមទំលាប់បុរាណ ដែលមានជាប់ទាក់ទងទៅនឹងធម្មជាតិ។
- ពិធីបុណ្យអុំទូក: ពិធីបុណ្យនេះធ្វើឡើងដើម្បីអបអរដល់រដូវកាលនៃសាទត្រី និង រដូវកាលប្រមូលផលស្រូវដោយបរិបូណ៌។
- ពិធីបុណ្យសមុទ្រ: ប្រារព្ធធ្វើឡើងក្នុងគោលបំណងជំរុញនិងលើកទឹកចិត្តដល់ការអភិរក្សធនធានសមុទ្រ។
- នៅក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័ល: តាមរយៈការអង្កេតគោឧសភរាជស៊ីចំណីនៅចុងពិធីបុណ្យនេះ ប្រជាជនកម្ពុជាមានជំនឿថាពួកគេនឹងអាចប្រមើលមើលព្រឹត្តការណ៍មួយចំនួនមានដូចជា ជំងឺរាត្បាត ទឹកជំនន់ ការប្រមូលផលដោយបរិបូណ៌និងកម្រិតទឹកភ្លៀង។
- នៅក្នុងពិធីបុណ្យសុំទឹកភ្លៀង: មានការបួងសួងដល់ព្រះ អារក្ខទេវតា ព្រមទាំងអ្នកតា ដើម្បីទទួលបានទឹកភ្លៀងបរិបូណ៌ក្នុងរដូវបង្កបង្កើនផល។



# លក្ខណៈពិសេសនៃធនធានធម្មជាតិនិងជីវៈចម្រុះរបស់ប្រទេសកម្ពុជា

- ប្រទេសកម្ពុជាគឺជាផ្នែកមួយដ៏សំខាន់នៃតំបន់ជីវៈចម្រុះតណ្ឌូភូមា។
- ជីវៈចម្រុះនៅប្រទេសកម្ពុជាមានច្រើនប្រភេទណាស់
  - រុក្ខជាតិប្រហែល ១៥០០ ប្រភេទ
  - ថនិកសត្វប្រហែល ២០០ ប្រភេទ
  - បក្សីសត្វប្រហែល ៧២០ ប្រភេទ
  - សត្វល្មូនប្រហែល ២៤០ ប្រភេទ
  - មច្ឆាប្រហែល ៨៥០ ប្រភេទនៅបឹងទន្លេសាប
  - មច្ឆានិងថនិកសត្វសមុទ្រប្រហែល ៤៣៥ ប្រភេទ
- សត្វត្រយងយក្សជាប្រភេទបក្សីតំណាងជាតិ អណ្តើកហ្លួងជាសត្វល្មូនតំណាងជាតិនិងត្រីគល់រាំងជាមច្ឆាតំណាងជាតិ។



# លក្ខណៈពិសេសនៃធនធានធម្មជាតិនិងជីវៈចម្រុះរបស់ប្រទេសកម្ពុជា

- ប្រទេសកម្ពុជាគឺជាតំបន់ដែលមាននៅសេសសល់ដងព្រៃលាតសន្ធឹងជាប់ៗគ្នា ហើយធំៗជាងគេនៅអាស៊ីអាគ្នេយ៍ដីគោក។
- បឹងទន្លេសាបគឺជាបឹងទឹកសាបធំជាងគេនិងជាបឹងមួយក្នុងចំណោមបឹងទឹកសាបដែលមានជីវៈចម្រុះសម្បូរបែបជាងគេនៅអាស៊ីអាគ្នេយ៍។
- ប្រព័ន្ធខ្សែទឹកទន្លេមេគង្គផ្តល់ធនធានទឹកដល់ការរស់នៅរបស់ប្រជាជនកម្ពុជារាប់លាននាក់ និងសត្វជាច្រើនប្រភេទ។
- ព្រៃឈើ តំបន់ដីសើមនិងទន្លេ ផ្តល់ទីជម្រកដល់រុក្ខជាតិនិងពពួកសត្វព្រៃជាច្រើនអនេក ហើយដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យមានលំនឹងអាកាសធាតុ។



# ការគំរាមកំហែងចំពោះការអភិវឌ្ឍនៅលើពិភពលោក: ការប្រែប្រួលអាកាសធាតុ

- ការប្រែប្រួលអាកាសធាតុគឺជាការគំរាមកំហែងដ៏ចម្បងមួយក្នុងចំណោមការគំរាមកំហែងយ៉ាងច្រើនផ្សេងទៀតចំពោះជីវៈចម្រុះក្នុងសកលលោកនិងជីវភាពរស់នៅរបស់មនុស្សទូទាំងចក្រវាលៈ
  - តាមរយៈសកម្មភាពមនុស្សដែលបានបណ្ដាលឱ្យមានការបំភាយឧស្ម័ន(ផ្សេងពុល) ចេញពីរថយន្ត យន្តហោះ រោងចក្រឧស្សាហកម្ម រោងចក្រផលិតថាមពល កសិដ្ឋានចិញ្ចឹមសត្វស្រុកខ្នាតធំនិងភ្លើងឆេះព្រៃ ដែលបន្ថែមឧស្ម័នទៅដល់បរិយាកាស ជាពិសេសគឺឧស្ម័នកាបូនិក។
  - ឧស្ម័នកាបូនិកបង្កើនសម្ពាធបរិយាកាសដើម្បីស្រូបយកកាំរស្មីព្រះអាទិត្យ ហើយបណ្ដាលឱ្យកំដៅផែនដីមានការកើនឡើង។
  - ការកើនឡើងនៃកំដៅផែនដីមានផលប៉ះពាល់ជាអវិជ្ជមានដោយផ្ទាល់ទៅលើអាកាសធាតុ ដែលនាំឱ្យមានស្ថានភាពអាកាសធាតុប្រែប្រួលធ្ងន់ធ្ងរដោយមិនអាចដឹងមុនបាន មានដូចជាគ្រោះរាំងស្ងួត ភ្លៀងធ្លាក់ខ្លាំងពេក ទឹកជំនន់និងព្យុះសង្ឃរា (ខ្យល់កន្ត្រាក់)។



# ការគំរាមកំហែងចំពោះការអភិរក្សនៅលើពិភពលោក:
# ការប្រែប្រួលអាកាសធាតុ

- សកម្មភាពរបស់មនុស្សជាច្រើនផ្សេងទៀតដូចជា:
  - ការកាប់ឈើ ការបំផ្លាញស្ថានប្រព័ន្ធសំខាន់ៗជាច្រើន (ព្រៃរងទឹកភ្លៀង ព្រៃរបោះ ព្រៃកោងកាងនិងព្រៃលិចទឹកជាដើម) បង្កឱ្យមានបញ្ហារៀបរាប់មកខាងលើនេះ កាន់តែខ្លាំងឡើងៗ។
- ការប្រែប្រួលអាកាសធាតុបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនយើងនៅប្រទេសកម្ពុជា:
  - បង្កឱ្យមានគ្រោះរាំងស្ងួតដែលធ្វើឱ្យយើងមានផលវិបាកក្នុងការដាំដំណាំកសិកម្ម ការចិញ្ចឹមសត្វស្រុក ហើយទីកន្លែងនេសាទត្រីអាចនឹងរីងស្ងួត
  - បង្កឱ្យមានគ្រោះទឹកជំនន់ អាចនឹងបំផ្លាញភូមិឋាននិងវាលស្រែវាលស្រូវ
  - រដូវប្រាំងកាន់តែក្តៅខ្លាំង រីងស្ងួតឡើងនិងមានរយៈពេលវែងជាងធម្មតា ហើយរដូវវស្សាមានរយៈពេលខ្លីជាងមុន ប៉ុន្តែមានភ្លៀងធ្លាក់ខ្លាំងនិងមានខ្យល់កន្ត្រាក់ច្រើន។



# ការគំរាមកំហែងចំពោះការអភិរក្សនៅប្រទេសកម្ពុជា

- ការកាប់បំផ្លាញព្រៃឈើនិងការបំផ្លិចបំផ្លាញទីជម្រក
- ការទាក់ចាប់សត្វ ការបរបាញ់សត្វនិងការជួញដូរសត្វព្រៃ
- បទល្មើសសត្វព្រៃដែលមានការរៀបចំជាប្រព័ន្ធ
- ការបំពុលដោយប្លាស្ទិក
- ការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតនិងសារជាតុពុលផ្សេងៗទៀតមិនបានត្រឹមត្រូវ
- ប្រភេទរាតត្បាត



# ការកាប់បំផ្លាញព្រៃឈើនិងការបំផ្លិចបំផ្លាញទីជម្រក

- ការកាប់ឆ្ការព្រៃឈើទ្រង់ទ្រាយធំដើម្បីយកដីដាំដំណាំកសិកម្មផ្សេងៗ មានដូចជាស្វាយចន្ទី ដំឡូងមី អំពៅនិងដើមកៅស៊ូជាដើម។
- ការកាប់ឈើទ្រង់ទ្រាយតូចដើម្បីចិញ្ចឹមជីវិត ការកាប់ឆ្ការព្រៃដើម្បីដាំដំណាំលក្ខណៈគ្រួសារ សាងសង់ផ្ទះនិងធ្វើធ្យូងដុត( ឡធ្យូង )។
- ការជួញដូរឈើ (គ្រឿងសង្ហារិម សាងសង់គេហដ្ឋាននិងផ្គត់ផ្គង់ឱ្យឡឥដ្ឋ ឡក្បឿង )
- ភ្លើងឆេះព្រៃ ( ទាំងគ្រោះធម្មជាតិនិងសកម្មភាពរបស់មនុស្ស )
- ទំនប់វារីអគ្គិសនីខ្នាតធំ
- សកម្មភាពបូមខ្សាច់និងបូមក្រួស





# ការទាក់ចាប់សត្វ ការបរបាញ់សត្វនិងការជួញដូរសត្វព្រៃ

រឿងដំរីព្រះពោធិសត្វៈ

រឿងនិទាននេះបង្ហាញអំពីការប្រកបមុខរបរចិញ្ចឹមជីវិតខុសរបស់ព្រានដំរី។

អ្នកប្រមាញ់សត្វព្រៃភាគច្រើននៅប្រទេសកម្ពុជាសព្វថ្ងៃនេះប្រកបមុខរបរនេះដោយខុសនឹងច្បាប់ដើម្បីបានប្រាក់ចំណូលបន្ថែម ដោយមានទាំងប្រភេទមានដោយកម្រ ដែលគេនាំចេញឆ្លងព្រំដែនទៅកាន់ប្រទេស ថៃឡុងដ៏ ចិន និងវៀតណាម។ ការជួញដូរសត្វព្រៃនិងសំណាកសត្វព្រៃបានក្លាយជាការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរចំពោះប្រភេទសត្វកម្រជាច្រើនប្រភេទមានដូចជាខ្លាដំបង ខ្លារខិន ខ្លាឃ្មុំ ពង្រូលនិងអន្សង។ ចំនួនសត្វទាំងនេះមានការថយចុះយ៉ាងឆាប់រហ័ស ជាលទ្ធផលនៃការបរបាញ់ ការទាក់ចាប់និងការបំផ្លាញជម្រកធម្មជាតិរបស់ពួកវា ដោយសារការកាប់ឈើលក្ខណៈទ្រង់ទ្រាយធំ។



# ការទាក់ចាប់សត្វ ការបរបាញ់សត្វនិងការជួញដូរសត្វព្រៃ

- ការជួញដូរធ្វើជាសត្វចិញ្ចឹម៖
  - ពពួកសត្វពានរ សត្វល្មូននិងសត្វស្លាប ត្រូវបានគេចាប់មកពីក្នុងព្រៃសម្រាប់លក់ដូរក្នុងជំនួញសត្វចិញ្ចឹមនិងការធ្វើបុណ្យកុសលតាមរយៈការលែងសត្វ។
- ឱសថបុរាណ៖
  - ឆ្អឹងខ្លា សំណាកសត្វរញ៉ី ស្រកាពង្រូល ស្នែងរមាស ហើយមានច្រើនផ្សេងទៀត។
- របស់ស័ក្តិសិទ្ធ ឬរបស់ការពារខ្លួន៖
  - ចៃតាន់ជ្រូកព្រៃនិងចង្កូមខ្លា
- របរចិញ្ចឹមជីវិត៖
  - ការបរបាញ់សត្វទ្រង់ទ្រាយតូច ការដាក់អន្ទាក់និងការនេសាទត្រី
- ដ័យភណ្ឌ (គ្រឿងលម្អផ្សេងៗ)៖
  - វត្ថុអនុស្សាវរីយ៍និងគ្រឿងតាំងលម្អផ្សេងៗទៀត



# បទល្មើសសត្វព្រៃដែលមានការរៀបចំជាប្រព័ន្ធ

- ជាទូទៅបទល្មើសទាំងនេះត្រូវបានគេរៀបចំឡើងជាលក្ខណៈអាជីព តាមមធ្យោបាយស្រដៀងគ្នាទៅនឹងបណ្តាញជួញដូរថ្នាំញៀននិងអាវុធខុសច្បាប់ ដោយចូលរួមរត់ពន្ធសត្វព្រៃឆ្លងដែនជាលក្ខណៈទ្រង់ទ្រាយធំ ដែលមានតម្លៃខ្ពស់ក្នុងទីផ្សារខុសច្បាប់ នៅឯបរទេស។
- បទល្មើសសត្វព្រៃដែលមានការរៀបចំជាប្រព័ន្ធបែបនេះក៏មានការចូលរួមសហការពីអ្នកភូមិក្នុងមូលដ្ឋានដើម្បីរកសត្វនិងទទួលបានសត្វយ៉ាងច្រើនដូចជាៈ
  - សត្វស្លាបចេះនិយាយ(ប្រភេទបក្សីចេះត្រាប់តាមសំលេងមនុស្ស)
  - សត្វពង្រូលនិងស្រកាពង្រូល
  - អណ្តើកទឹកនិងអណ្តើកគោក
  - សំណាកសត្វខ្លា
  - ភ្លុកដំរីនិងកុយរមាស



# ការបំពុលដោយប្លាស្ទិក

- ការបំពុលដោយប្លាស្ទិកៈ
  - កាកសំណល់ ជាតិពុលនិងការប្រែប្រួលអាកាសធាតុ
- ប្លាស្ទិកមានគ្រោះថ្នាក់ចំពោះ
  - សុខភាពរបស់មនុស្ស
  - ប្រភពទឹកក្រោមដីរបស់យើង
  - សត្វព្រៃរបស់យើង
- ប្លាស្ទិកប្រមូលផ្តុំនៅក្នុងបរិស្ថាន (ហូរចាក់ចូលទៅក្នុងស្ទឹង បឹង ទន្លេនិងមហាសមុទ្រ)
- មិនទាន់មានប្រព័ន្ធកែច្នៃប្លាស្ទិកឡើងវិញនៅក្នុងប្រទេស។



# ការបំពុលដោយប្លាស្ទិក

- ប្លាស្ទិកមិនងាយរលាយបាត់ទាំងស្រុងឡើយ:
  - វាបែកជាបំណែកតូចៗ ហើយល្អិតៗ
  - មីក្រូប្លាស្ទិក( Microplastics) ពេលដែលប្លាស្ទិកក្លាយជាបំណែកតូចៗដែលយើងមើលស្ទើរតែលែងឃើញនឹងត្រូវដក់ជាប់នៅក្នុងខ្លួនសត្វស្ទើរតែទាំងអស់
- ប្លាស្ទិកធ្វើឱ្យអាហាររបស់យើងមានជាតិពុល
  - ការកកសន្សំក្នុងភាវៈរស់( Bioaccumulation )គឺជាការកើនឡើងនូវបណ្ដុំសារជាតុពុលនៅក្នុងសារពាង្គកាយមានដូចជាមីក្រូប្លាស្ទិកនិងថ្នាំសម្លាប់សត្វល្អិត តាមរយៈខ្សែអាហារនិងបណ្ដាញអាហារ



# ការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតនិងសារធាតុពុលផ្សេងទៀតមិនបានត្រឹមត្រូវ

- ថ្នាំសម្លាប់សត្វល្អិតមានគ្រោះថ្នាក់ណាស់ វាមានសារជាតុពុល ដែលធ្វើឱ្យប៉ះពាល់ទៅដល់សុខភាពមនុស្សនិងសត្វផងដែរ។
- ថ្នាំនេះវានឹងសម្លាប់សត្វល្អិតមានប្រយោជន៍មួយចំនួនផងដែរ ដូចជាឃ្មុំដែលជាភ្នាក់ងារដំណើរលំអងដ៏សំខាន់បំផុត ដូច្នោះហើយវាក៏ផ្តល់ផលប៉ះពាល់ជាអវិជ្ជមានដល់ឋានប្រព័ន្ធផងដែរ។
- មនុស្សប្រើថ្នាំសម្លាប់សត្វល្អិតសម្រាប់ការប្រមាញ់សត្វ ការនេសាទ ឬក៏យកទៅប្រើប្រាស់ដើម្បីការពារផលដំណាំ ពីការបំផ្លាញរបស់សត្វស្រុក។
- សត្វដែលស្លាប់ដោយសារថ្នាំពុលនឹងមានជាតិពុលជ្រាបចូលសព្វសរីរាង្គនិងសាច់របស់វា។ ប្រសិនបើមនុស្សបរិភោគសាច់សត្វទាំងនោះហើយ ប្រៀបដូចជាពួកគេលេបថ្នាំពុលយ៉ាងហ្នឹងដែរ បន្ទាប់មកពួកគេនឹងទទួលរងផលប៉ះពាល់ជាអវិជ្ជមានយ៉ាងធ្ងន់ធ្ងរដល់សុខភាព។
  - ការកកសន្សំក្នុងភាវៈរស់ ( Biomagnification/ bioaccumulation ) មើលទំព័រ៣០។






# ប្រភេទរាតត្បាត

- បើយោងទៅតាមមជ្ឈមណ្ឌល អេ ស៊ី ប៊ី ACB ( Asean Centre for Biodiversity ) នៅប្រទេសកម្ពុជាមានប្រភេទរាតត្បាត ដែលត្រូវបានគេកត់ត្រាចំនួនប្រហែលជា ៦៣ប្រភេទ
  - ប្រភេទរាតត្បាតគឺជាប្រភេទដែលមិនមែនមានដើមកំណើតនៅតំបន់ជាក់លាក់ណាមួយឡើយ។
  - សត្វនិងរុក្ខជាតិទាំងអស់អាចក្លាយជាប្រភេទតាត្បាតបាននៅពេលដែលត្រូវបានគេនាំមកដោយមានគោលបំណង ឬ ដោយអចេតនាឱ្យទៅរស់នៅក្នុងជម្រកណាមួយដែលមិនមែនជាកន្លែងកំណើតរបស់ពួកវា ហើយវាក៏អាចដណ្តើមជម្រកសត្វក្នុងតំបន់បានដែរ។
  - ប្រភេទរាតត្បាតអាចបណ្តាលឱ្យមានផលប៉ះពាល់ជាអវិជ្ជមានយ៉ាងធ្ងន់ធ្ងរដល់សេដ្ឋកិច្ច ការគំរាមកំហែងដល់បរិស្ថាននៅក្នុងតំបន់។





# តើអ្នកអាចធ្វើអ្វីបានខ្លះដើម្បីជួយដល់ការអភិរក្សនៅក្នុងតំបន់?




- សូមប្រើប្រាស់ធនធានធម្មជាតិឱ្យមាននិរន្តរភាពជាងមុន
- ប្រើប្រាស់រុក្ខជាតិដែលផ្តល់ប្រភពប្រូតេអ៊ីនក្នុងរបបអាហាររបស់អ្នកនិងធ្វើជាឱសថបុរាណ។ ប្រើប្រាស់ឱសថបុរាណនិងប្រភេទចំណីអាហារដែលមាននិរន្តរភាព
- កាត់បន្ថយការជួញដូរសត្វព្រៃតាមរយៈការលើកម្ពស់ការយល់ដឹង
- សូមកាត់បន្ថយការប្រើប្រាស់សម្ភារៈប្លាស្ទិកដែលប្រើតែមួយដងបោះចោល
- សូមប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតឱ្យបានត្រឹមត្រូវ

# សូមប្រើប្រាស់ធនធានធម្មជាតិឱ្យមាននិរន្តរភាពជាខមុន

- សូមប្រើប្រាស់គ្រឿងសង្ហារិមនិងគ្រឿងតុបតែងធ្វើពីប្រភេទឈើដែលលូតលាស់លឿនដូចជាដើមឫស្សី ដើមស្លា ដើមប្រេងខ្យល់ ឬ ដើមអាកាស្យាជាដើម
- សូមប្រើឱសថបុរាណធ្វើពីប្រភេទរុក្ខជាតិតាមទំលាប់បុរាណ មានដូចជាស្លឹកគ្រៃ រមៀតនិងខ្ញីជាដើម ហើយប្រមូលដើមរុក្ខជាតិនិងស្លឹករុក្ខជាតិណាដែលលូតលាស់លឿន
- ប្រមូលទឹកឃ្មុំឱ្យមាននិរន្តរភាព ការចិញ្ចឹមឃ្មុំ ការដាក់បង្គងយកទឹកឃ្មុំនឹងការប្រមូលជ័រទឹក
- កុំដុតព្រៃឈើបំផ្លាញទីជម្រកសំខាន់ៗ វានឹងផ្តល់ផលប៉ះពាល់ដល់សត្វជាច្រើន ហើយធ្វើឱ្យកំដៅផែនដីកើនឡើង ដោយសារការបញ្ចេញនូវឧស្ម័នកាបូនិកដ៏ច្រើនលើសលប់ពេក។



# ប្រើប្រាស់រុក្ខជាតិដែលផ្តល់ប្រភពប្រូតេអ៊ីនក្នុងរបបអាហាររបស់អ្នកនិងធ្វើជាឱសថបុរាណ។ ប្រើប្រាស់ឱសថបុរាណនិងប្រភេទចំណីអាហារដែលមាននិរន្តរភាព

- សូមប្រើប្រាស់រុក្ខជាតិដែលផ្តល់ប្រភពប្រូតេអ៊ីននិងសត្វដែលសំបូរច្រើន (មិនមែនប្រភេទកម្រ)
- សូមប្រើប្រាស់ឱសថបុរាណដែលផលិតពីរុក្ខជាតិ
- ជំងឺភាគច្រើនអាចព្យាបាលបានជាសះស្បើយប្រកបដោយប្រសិទ្ធភាពខ្ពស់ ដោយការប្រើថ្នាំពេទ្យនៅក្នុងមន្ទីរសម្រាកព្យាបាល ឬ មណ្ឌលសុខភាព






# កាត់បន្ថយការជួញដូរសត្វព្រៃតាមរយៈការលើកកម្ពស់ការយល់ដឹង

- សត្វព្រៃមិនស្រួលចិញ្ចឹមទេដូច្នេះហើយពួកវាមិនគួររក្សាទុកដូចសត្វចិញ្ចឹមឡើយ។
- ការទិញសត្វពីការជួញដូរសត្វព្រៃ ធ្វើបែបនេះហាក់ដូចជាជំរុញឱ្យកាន់តែមានជំនួញទុច្ចរិតទាំងនេះកើតឡើងជាបន្តទៀត។
- សត្វព្រៃបានមកពីការជួញដូរខុសច្បាប់ភាគច្រើនឈឺហើយចាំបាច់ត្រូវការអ្នកឯកទេសថែទាំត្រឹមត្រូវដើម្បីអាចលែងទៅក្នុងព្រៃធម្មជាតិវិញ។



# សូមកាត់បន្ថយការប្រើប្រាស់សម្ភារប្លាស្ទិកដែលប្រើតែម្ដងបោះចោល

គោលការណ៍ ៤ R

- បដិសេធមិនប្រើ
- កាត់បន្ថយការប្រើ
- ការប្រើប្រាស់ឡើងវិញ
- ការកែច្នៃឡើងវិញ



# សូមប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតឱ្យបានត្រឹមត្រូវ

- ប្រសិនបើមិនអាចជៀសវាងបាន ថ្នាំសម្លាប់សត្វល្អិតគួរតែប្រើចំពោះតែដំណាំកសិកម្មប៉ុណ្ណោះ។
- ថ្នាំសម្លាប់សត្វល្អិតមិនគួរប្រើក្នុងទង្វើមិនសមរម្យមួយចំនួនដូចជាការប្រើថ្នាំសម្លាប់សត្វល្អិតដើម្បីបំពុលសត្វព្រៃជាដើមៈ
  - ត្រី
  - សត្វស្លាប
  - ប្រភេទសត្វព្រៃផ្សេងទៀត



# ច្បាប់និងបទបញ្ញត្តិផ្សេងៗ៖

# ការអភិរក្សសត្វព្រៃ(ជំពូក ទី១០)

យោងទៅតាមច្បាប់នៃប្រទេសកម្ពុជាដែលបានចែងយ៉ាងច្បាស់ថា យើងត្រូវការពារសត្វព្រៃទាំងអស់ ហើយរាល់សកម្មភាពបរបាញ់សត្វ ការដាក់អន្ទាក់សត្វ ការប្រមាញ់សត្វ ការជួញដូរនិងការចិញ្ចឹមសត្វព្រៃ គឺជាអំពើខុសច្បាប់ស្ទើរគ្រប់ករណីទាំងអស់។

ច្បាប់ស្តីពីព្រៃឈើនៅប្រទេសកម្ពុជា (ឆ្នាំ ២០០២) ជំពូកទី១០ (មាត្រា៤៨ -៥០) បានចែងថា៖

**មាត្រា ៤៨៖**

ពពួកសត្វព្រៃគ្រប់ប្រភេទទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាគឺជាទ្រព្យសម្បត្តិរបស់រដ្ឋនិងជាសមាសភាគធនធានព្រៃឈើដែលរួមមានៈ ពួកថនិកសត្វ បក្សីសត្វ ឧរង្គសត្វ ថលជលិកសត្វ បាណកសត្វនិងសត្វឥតឆ្អឹងកងផ្សេងទៀតព្រមទាំងពងកូនរបស់វា។ ពពួកសត្វព្រៃទាំងអស់នេះស្ថិតនៅក្រោមការគ្រប់គ្រង ការសិក្សាស្រាវជ្រាវនិងការអភិរក្សដោយរដ្ឋបាលព្រៃឈើ ដោយមិនរាប់បញ្ចូលត្រីនិងសត្វបង្កកំណើតក្នុងទឹក។

សំណាកសត្វព្រៃ គឺជាសត្វព្រៃដែលស្លាប់ ទោះជានៅខ្លួនទាំងមូល សិរីរាង្គក្នុង សិរីរាង្គក្រៅ បំណែកឆ្អឹង ឬ ផលិតផលកែច្នៃ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើ។ គ្រប់ប្រភេទសត្វព្រៃទាំងអស់ ត្រូវបានបែងចែកជាបីក្រុមគឺៈ ក្រុមប្រភេទជិតផុតពូជ ក្រុមប្រភេទមានដោយកម្រ ក្រុមប្រភេទមានដោយបង្គួរ។

# ការអភិរក្សសត្វព្រៃ( ជំពូក ទី១០ )

ច្បាប់ស្តីពីព្រៃឈើនៅប្រទេសកម្ពុជា ( ឆ្នាំ ២០០២ ) ជំពូកទី១០ (មាត្រា៤៨ -៥០ ) បានចែងថា៖

**មាត្រា ៤៩៖**

ហាមឃាត់ដាច់ខាតរាល់ការបរបាញ់សត្វ ការឃាឃី ឬការរំខានដល់សត្វព្រៃគ្រប់ប្រភេទ ដោយប្រើប្រាស់ឧបករណ៍គ្រោះថ្នាក់គ្រប់ប្រភេទ ការបរបាញ់សត្វក្នុងរដូវកាលហាមឃាត់និងនៅក្នុងតំបន់អភិរក្ស។ ចំពោះប្រភេទសត្វកម្រនិងកំពុងរងគ្រោះជិតផុតពូជបំផុត ជាទូទៅត្រូវបានហាមឃាត់រាល់សកម្មភាពទាំងអស់ដូចជា ការបរបាញ់ ការឃាឃី ការដាក់អន្ទាក់ ការដាក់អង្គប់ ការបំពុល ការដឹកជញ្ជូន ការជួញដូរ ការនាំចេញនិងនាំចូល ព្រមទាំងការចិញ្ចឹមសត្វទាំងនោះ ក្នុងសួនសត្វ ឬនៅតាមផ្ទះ។

**មាត្រា ៥០៖**

ចំពោះប្រភេទសត្វមានដោយបង្គួរមួយចំនួន អាចអនុញ្ញាតឱ្យចិញ្ចឹមក្នុងសួនសត្វ ឬ តាមផ្ទះបាន។ ប៉ុន្តែរាល់ការនាំចេញនិងនាំចូលប្រភេទសត្វទាំងនោះ អាចធ្វើទៅបានលុះត្រាតែមានលិខិតអនុញ្ញាតចេញដោយរដ្ឋបាលព្រៃឈើជាមុនសិន។

# ការការពារ និងការអភិរក្សជលផល( ជំពូក ទី៥ )

ច្បាប់ស្តីពីជលផលនៅប្រទេសកម្ពុជា ( ឆ្នាំ ២០០៦ ) ជំពូកទី០៥ (មាត្រា២០និង២៣ ) បានចែងថា៖

**មាត្រា ២០៖**

ហាមឃាត់ដាច់ខាតចំពោះការប្រើឧបករណ៍នេសាទមួយចំនួនមានដូចជា ឧបករណ៍ឆក់ គ្រឿងផ្ទុះនិងសារធាតុពុលផ្សេងៗទៀត ឧបករណ៍បូមបាចពង្រីងផ្នែកណាមួយនៃដែននេសាទ ច្បូក សាង ស្ន មង ឬ អួន ដែលមានក្រឡាតូចជាង ១.៥ ស.ម ឬ មានក្រឡាធំជាង ១៥ ស.ម ក្នុងដែននេសាទទឹកសាបនិងទំនប់រួមផ្សំដោយឧបករណ៍គ្រប់ប្រភេទ។ល។

**មាត្រា ២៣៖**

សកម្មភាពដូចមានរៀបរាប់ខាងក្រោមអាចប្រព្រឹត្តទៅបានលុះត្រាតែមានការអនុញ្ញាត៖

ការចាប់ ការលក់ ការទិញ ការធ្វើសន្និធិនិងការដឹកជញ្ជូន កូន ឬ ពងត្រីនិងកូន ឬ ពងវារីសត្វផ្សេងៗទៀត។

ការចាប់ ការលក់ ការទិញ ការដឹកជញ្ជូន កូន ការប្រមូលផលនិងការធ្វើសន្និធិ នូវប្រភេទធនធានជលផលកំពុងរងគ្រោះថ្នាក់។

# មក្តុទ្ទេសក៍ឆ្ពោះទៅស្គាល់
# ប្រភេទសត្វសំខាន់ៗដែលព្រះសង្ឃអែមខជួបប្រទះ

NE DD LC NT **VU** VULNERABLE EN CR EW EX

RED LIST

# ស្វាក្តាម

## Common Long-tailed Macaque

## *Macaca fascicularis*



**ភិនភាគ**

កន្ទុយវែងជាងប្រវែងដងខ្លួន មុខពណ៌ផ្កាឈូកចាស់ហើយមានឆ្នូតពណ៌ស លើរង្វង់ភ្នែកសងខាងខ្ទង់ច្រមុះ។ នៅលើក្បាល មានកំប៉ោយនៅចុងប៉ូចក្បាល ដែលបាស់ឡើងលើថ្ងាស។ ឈ្មោលសម្គាល់បានត្រង់មានពុកមាត់ និងរោមថ្ពាល់ជុំវិញមុខរបស់វា។ ញីមានពុកចង្កានិងរោមថ្ពាល់។

**ទីជម្រក**

ព្រៃតំបន់ទំនាបនិងព្រៃពាក់កណ្តាលស្រោង ព្រៃស្បាត ព្រៃប្របមាត់ស្ទឹង ព្រៃតំបន់ឆ្នេរនិងព្រៃកោងកាង។

**ការគំរាមកំហែង**

បាត់បង់ទីជម្រក ការបរបាញ់យកសាច់ធ្វើជាអាហារ ការជួញដូរខុសច្បាប់ និងការស្រាវជ្រាវផ្សេងៗ (ប្រើប្រាស់ជាវត្ថុសម្រាប់ធ្វើការពិសោធន៍)។

**របាយរស់នៅ**

អាស៊ីអាគ្នេយ៍ ខាងត្បូងឆៀងខាងកើតបង់ក្លាដែស កោះផ្ទានិងកោះបូណេអូ។

**របបអាហារ**

**សព្វាសី:** ផ្លែឈើនិងគ្រាប់ធញ្ញជាតិជាចំណីរបស់វាស្មើរតែ៩០% ប៉ុន្តែពួកវាក៏ស៊ីស្លឹកឈើ ផ្កា សំបកឈើ ស៊ុត កូនសត្វស្លាប ល្អូនតូចៗ ថលជលិក ត្រីនិងសត្វឥតឆ្អឹងកង។

# ស្វាត្រោស

## Northern Pig-tailed Macaque

## *Macaca Leonina*

NE DD LC NT **VU** VULNERABLE EN CR EW EX



**ភិនភាគ**

មាឌធំរាងក្រអាញ រោមពណ៌ប្រផេះត្នោត ហើយនៅលើក្បាលមានក្រយៅពណ៌ត្នោតចាស់ហើយមានរោមខ្លីបះត្រង់មើលទៅរាងដូចម្ជុកកន្ទ្រីប។ មុខរបស់វាពណ៌ផ្កាឈូក ដោយមានផ្នត់ស្បែកស្រអាប់នៅជុំវិញភ្នែក ហើយមានឆ្នូតពណ៌ក្រហមចាប់ពីចុងកន្ទុយភ្នែកភ្ជាប់ទៅចុងថ្ពាសខាងក្រោម។ នៅជុំវិញថ្ពាល់មានរោមកញ្ចុំវែងពណ៌ប្រផេះ ស្ទើរតែលុបបាត់ត្រចៀក។ ស្វាត្រោសមានលក្ខណៈខុសពីស្វាដ៏ទៃត្រង់កន្ទុយក្រាស់ហើយខ្លី កោងដូចទម្ពក់បះឡើងលើខ្នង (ស្រដៀងកន្ទុយជ្រូក)។

**ទីជម្រក**

ព្រៃឫស្សី ព្រៃរបោះ ព្រៃពាក់កណ្ដាលស្រោងនិងព្រៃស្រោង។

**ការគំរាមកំហែង**

ការបាត់បង់ទីជម្រក ការបរបាញ់យកសាច់និងសំណាកសត្វ ការចាប់ដោយខុសច្បាប់លក់ដូរធ្វើជាសត្វចិញ្ចឹម។

**របបអាហារ**

ផ្លែឈើជាង១០០ប្រភេទ ពងសត្វនិងសត្វតូចៗ ព្រមទាំងសត្វឥតឆ្អឹងកងជាច្រើនទៀត។

**រប៉ាយរស់នៅ**

ប្រទេសកម្ពុជា ឥណ្ឌា បង់ក្លាដែស ភូមា ថៃឡង់ដ៍  ចិន លាវនិងវៀតណាម។

# ទោចម្កុដ

## Pileated Gibbon

## *Hylobates pileatus*

NE DD LC NT VU ‹ EN › CR EW EX

ENDANGERED



**ភិនភាគ**

ដងខ្លួនរាងវៀរខាងក្រោម ដៃវែង គ្មានកន្ទុយ ហើយគូទក្រិន។ ទោចម្កុដមានលក្ខណៈងាយស្រួលក្នុងការសម្គាល់ថាញី ឬ ឈ្មោល ដោយញីមានសម្បុរទង់ដែង តែឈ្មោលសម្បុរខ្មៅ។ ឈ្មោលនៅវ័យក្មេងសម្បុរត្នោតរហូតដល់វ័យបន្តពូជ។ ញីមានបណ្តុំរោមពណ៌ខ្មៅចាប់ពីចុងប៉ូចក្បាលរហូតដល់ក្រលៀន។ ទាំងពីរភេទ ជាធម្មតាមានស្នាមឆ្នូតរាងរង្វង់ពណ៌សព័ទ្ធជុំវិញចុងប៉ូចក្បាលនិងសងខាងក្បាល។

**ទីជម្រក**

ព្រៃដែលមានសំណើមខ្ពស់ ព្រៃស្រោងនិងព្រៃចម្រុះលាយគ្នារវាងព្រៃស្រោងនិងព្រៃរបោះ។ ពួកវាចូលចិត្តរស់នៅលើដើមឈើខ្ពស់ៗ។

**ការគំរាមកំហែង**

ការបាត់បង់ទីជម្រក ការបែកខ្ញែកទីជម្រកនិងការបរបាញ់។

**របបអាហារ**

ចំណីរបស់វាគឺផ្លែឈើ។ ក្រៅពីនេះមានស្លឹកឈើ សត្វល្អិត ពងសត្វនិងសត្វឆ្អឹងកងតូចៗមួយចំនួនដូចជាបក្សីសត្វ។

**របាយរស់នៅ**

ប្រទេសកម្ពុជា ថៃឡង់និងលាវ។

NE DD LC NT VU **EN** ENDANGERED CR EW EX

# រញ្ជីប្រផេះ

## Bengal Slow Loris

## *Nycticebus bengalensis*



**ភិនភាគ**

រោមខ្នងពណ៌ត្នោតព្រលែត រោមពោះពណ៌ត្នោតព្រលែតជាងរោមខ្នងបន្តិច។ មុខពណ៌សភ្លឺ ហើយមានបណ្តុំរោមពណ៌ត្នោតចាស់រាងត្រីកោណជុំវិញភ្នែក។ មានឆ្នូតរាងស្រអាប់ចាប់ពីកណ្តាលក្បាល ដោយប្រែប្រួលពណ៌ទៅជាត្នោតចាស់នៅស្មា ហើយបន្តដូចឆ្នូតខ្នង រហូតដល់ពាក់កណ្តាលខ្នង។

**ជម្រក**

ព្រៃស្រោងក្នុងតំបន់ត្រូពិច ព្រៃពាក់កណ្តាលស្រោងនិងព្រៃរបោះដែលមានសំណើមខ្ពស់។ ពួកវាក៏រស់នៅតាមដំណុះព្រៃក្មេង តាមជាយព្រៃព្រហ្មចារីនិងតាមទំនប់កសិកម្ម ព្រមទាំងព្រៃឫស្សី។

**ការគំរាមកំហែង**

ការបាត់បង់ទីជម្រក ព្រមទាំងការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរពីការបរបាញ់ដើម្បីយកសាច់ ធ្វើឱសថបុរាណនិងដើម្បីផ្គត់ផ្គង់ដល់ការជួញដូរធ្វើជាសត្វចិញ្ចឹម។

**រប៉ាយរស់នៅ**

ប្រទេសកម្ពុជា ឥណ្ឌា បង់ក្លាដែស ភូមា ចិន លាវ និងវៀតណាម។

**របបអាហារ**

ចំណីរបស់ពួកវាភាគច្រើនជ័រឈើ ប៉ុន្តែពួកវាក៏ស៊ីសត្វល្អិត ផ្លែឈើ បង្គួយនិងថនិកសត្វតូចៗផងដែរ។

# ញ៉ើក្លើង

## Pygmy Slow Loris

## *Nycticebus pygmaeus*

NE DD LC NT VU **EN** CR EW EX

RED LIST — ENDANGERED



**ភិនភាគ**

រោមខ្នងខ្លីៗហើយក្រាស់ពណ៌ត្នោតភ្លឺលាយនឹងពណ៌ទឹកក្រូចស្រាល។ លើផ្ទៃមុខមានឆ្នូតពណ៌សចាប់ពីខ្នង់ប្រមុះរហូតដល់ថ្ងាសនិងភ្ជាប់ទៅនឹងឆ្នូតខ្នង។ រញ៉ើភ្លើងមានប្រមុះពណ៌ខ្មៅ ប្រអប់ដៃនិងជើងមានស្បែកពណ៌ខ្មៅមានរោមខ្លីលើត្រចៀកដែលលេចចេញមកយ៉ាងច្បាស់។

**ទីជម្រក**

ព្រៃព្រហ្មចារី ព្រៃពាក់កណ្ដាលស្រោងនិងព្រៃដុះឡើងវិញ ប៉ុន្តែពួកវាក៏រស់នៅក្នុងព្រៃចុល្លិសិលា ព្រៃឫស្សីនិងព្រៃរេចរឹលផងដែរ។

**ការគំរាមកំហែង**

ការជួញដូរធ្វើជាអាហារ  ឱសថបុរាណនិងការគំរាមកំហែងយ៉ាងខ្លាំងពីការជួញដូរធ្វើជាសត្វចិញ្ចឹមក្នុងទីផ្សារអន្តរជាតិ។

**របៀបរស់នៅ**

ភាគខាងកើតទន្លេមេគង្គនៅក្នុងប្រទេសកម្ពុជា និងវៀតណាម លាវនិងភាគខាងត្បូងប្រទេសចិន។

**របបអាហារ**

ជាទូទៅពួកវាស៊ីសត្វល្អិតនិងសំបកឈើខ្ចីៗ ប៉ុន្តែវាក៏យកទឹកដមរុក្ខជាតិស៊ីបង្គួយ ថនិកសត្វតូចៗ ស៊ុតនិងកូនសត្វផងដែរ។

# ស្វាព្រាម

## Indochinese Silvered Langur
## *Trachypithecus germaini*

NE DD LC NT VU EN ENDANGERED CR EW EX



**រូបរាង**

មានរោមវែងៗពណ៌ខ្មៅ-ប្រផេះពាសពេញលើដងខ្លួន។ កន្ទុយវែងពណ៌ប្រផេះដែរ។ មានស្បែកមុខពណ៌ប្រផេះចាស់ហើយព័ទ្ធជុំវិញដោយរោមវែងៗពណ៌សថ្លា ដែលដុះវែងកញ្ចុំជាកំប៉ោយនៅចុងប៉ូចក្បាល។ កូនស្វាព្រាមពណ៌ទឹកក្រូច។ ដៃជើងមានពណ៌ប្រផេះចាស់ ឬខ្មៅ។

**ទីជម្រក**

វាលទំនាប ព្រៃពាក់កណ្ដាលស្រោង ព្រៃស្រោងនិងព្រៃកោងកាង។

**ការគំរាមកំហែង**

ការបាត់បង់ទីជម្រក ការបរបាញ់ ឱសថបុរាណនិងការប្រមូលជួញដូរធ្វើជាសត្វចិញ្ចឹម។

**របបអាហារ**

ស្លឹកឈើខ្ចីៗនិងស្លឹកឈើចាស់ (ស្ទើរតែ ៧០%) ផ្លែឈើនិងផ្កា (ប្រហែល ២៥%) និងពន្លកឈើ (ប្រហែល ៥%)។

**របាយរស់នៅ**

ប្រទេសកម្ពុជា លាវ ភូមា ថៃឡង់ដ៍និងវៀតណាម។

NE DD LC LEAST CONCERN NT VU EN CR EW EX

# ឆ្មាដាវ

## Leopard Cat

## *Prionailurus bengalensis*



© ACCB/Daniel Roper-Jones

**ភិនភាគ**

មាឌប៉ុនឆ្មាស្រុកប៉ុន្តែឆ្មាដាវមានជើងវែងជាង។ សម្បុររបស់វាតាមលំដាប់ពណ៌ចាប់ពីទឹកក្រូចលាយត្នោត រហូតដល់ពណ៌លឿង ក្រហម ឬ ប្រផេះនៅផ្នែកខាងលើ ហើយសម្បុរផ្នែកខាងក្រោមពណ៌សអុចៗ។ លើដងខ្លួនផ្នែកចំហៀងពណ៌ក្រហមក្រមៅ មានដុំអុចៗរត់ជាជួររហូតដល់ជើងនិងកន្ទុយ។ វាមានឆ្នូតពណ៌ខ្មៅ៤ ចាប់ផ្តើមចេញពីលើថ្ងាស ដល់កញ្ចឹងក រហូតដល់ស្មា។ ឆ្មាដាវតែងតែមានឆ្នូត១ រត់ត្រង់លើបណ្តោយដងខ្លួន។

**ទីជម្រក**

វារស់នៅក្នុងជម្រកផ្សេងៗ ចាប់ពីព្រៃរងទឹកភ្លៀងតំបន់ត្រូពិច រហូតដល់ព្រៃរនាម ព្រៃដុះឡើងវិញនិងតំបន់កសិកម្ម។

**ការគំរាមកំហែង**

ការបាត់បង់ទីជម្រក ការបរបាញ់និងត្រូវបានគេសម្លាប់ដោយសារវាចាប់សត្វចិញ្ចឹមស៊ី ការធ្វើអាជីវកម្មទ្រង់ទ្រាយធំនៅប្រទេសចិនដើម្បីយករោមយកសាច់និងការជួញដូរធ្វើជាសត្វចិញ្ចឹម។

**របាយរស់នៅ**

ប្រទេសកម្ពុជា លាវនិងវៀតណាម។

**របបអាហារ**

ថនិកសត្វតូចៗ បក្សីសត្វតូចៗ ល្មូនតូចៗនិងសត្វល្អិត ព្រមទាំងត្រីនិងខ្យង ក្តាមផងដែរ។

# សំពោចក្រអូប

## Common Palm Civet

## *Paradoxurus hermaphroditus*

NE | DD | LC LEAST CONCERN | NT | VU | EN | CR | EW | EX



**រូបរាង** ដងខ្លួនវែង កន្ទុយវែង ជើងខ្លី។ ច្រមុះស្រួចលយចេញផុតពីទម្រង់មុខដ៏តូចរបស់វា។ វាមានភ្នែកធំពណ៌ស្រអាប់និងត្រចៀកធំស្រួច។ រោមខ្លួនខ្លីហើយគ្រើមជាធម្មតាពណ៌ខ្មៅ ឬ ប្រផេះ ដោយមានរោមការពារពណ៌ខ្មៅអុចៗនៅពាសពេញខ្លួន។ មានបណ្តុំរោមពណ៌សនៅខាងក្រោមនិងខាងលើភ្នែក ព្រមទាំងសងខាងច្រមុះ។ វាមានធ្នូតពណ៌ស្រអាប់នៅក្រោមខ្នងស្នាមអុចៗពណ៌ខ្មៅពាដូរនៅសងខាងតួខ្លួនរបស់វានិងគ្របដណ្តប់លើជើងទាំង៤របស់វា។

**ទីជម្រក** ពួកវារស់នៅក្នុងជម្រកផ្សេងៗ មានដូចជាព្រៃស្រោងនិងព្រៃរបោះ ព្រៃលិចទឹកតាមរដូវ ព្រៃកោងកាងនិងតំបន់កសិកម្ម។

**ការគំរាមកំហែង** ការបរបាញ់យកសាច់និងសំណាកដើម្បីផ្គត់ផ្គង់ឱ្យទីផ្សារអន្តរជាតិនិងការផលិតកាហ្វេលាមកសំពោច។

**របាយរស់នៅ** មានវត្តមាននៅពាសពេញអាស៊ីអាគ្នេយ៍និងអាស៊ីខាងត្បូង។

**របបអាហារ** ចំណីរបស់វាមានដូចជាសត្វល្អិតនិងផ្លែឈើ ក្នុងចំណោមផ្លែឈើជាច្រើនប្រភេទក៏មានផ្លែកាហ្វេសីរីហ្សផងដែរ។

NE DD **LC** LEAST CONCERN NT VU EN CR EW EX

# ស្កាតូច

## Javan Mongoose

## *Herpestes javanicus*



ស្កាតូចមានមាឌតូច ជើងខ្លី ហើយមានត្រចៀកមូលតូចនៅសងខាងក្បាលរបស់វា។ វាមានរោមទន់ហើយខ្លី ជាធម្មតាមានពណ៌ព្រលែត ឬ ត្នោតចាស់ ដោយមានស្នាមអុចតូចៗពណ៌មាស ប៉ុន្តែវាអាចមានលក្ខណៈប្រែប្រួលទៅតាមរដូវកាល។ វាមានពណ៌ព្រលែតនៅផ្នែកខាងក្រោមនិងមានកន្ទុយសំពោង។

**ទីជម្រក**

ព្រៃរនាម វាលស្មៅ ដំណាំចំការធំៗ តំបន់កសិកម្មនិងវាលស្រែវាលស្រូវ។

**ការគំរាមកំហែង**

ប្រភេទនេះមិនទាន់មានការគំរាមកំហែងសំខាន់ណាមួយឡើយ។

**របាយរស់នៅ**

ប្រទេសកម្ពុជា វៀតណាម ថៃឡង់ដ៍ លាវ ភូមា និង ម៉ាឡេស៊ី( ស៊ូម៉ាត្រា ជ្វានិងប៉ាលី )។

**របបអាហារ**

ចំណីរបស់វាគឺពួកសត្វឆ្អឹងកង មានទាំងកង្កែបផង ពួកល្មូននិងថនិកសត្វតូចៗ ប៉ុន្តែក៏មានពួកសត្វឥតឆ្អឹងកងដូចជាសត្វល្អិតផងដែរ។

NE DD LC NT VU VULNERABLE EN CR EW EX

# ខ្លាឃ្មុំតូច

## Sun Bear

## *Helarctos malayanus*




**រូបរាង**

ត្រចៀកមូលខ្លី ហើយដងខ្លួនគ្របដណ្តប់ទៅដោយរោមខ្លីក្រាស់ពណ៌ខ្មៅរលោង។ ច្រមុះនិងមាត់ខ្លីពណ៌ប្រផេះ ឬពណ៌ទឹកក្រូចព្រឿងៗ។ ឆ្នូតដើមទ្រូងពណ៌លឿង ឬ ពណ៌ស្លេក មានរាងដូចជាលោកខែ។ ច្រមុះនិងមាត់របស់វាខ្លីជាង ពណ៌ភ្លឺជាងខ្លាឃ្មុំធំ ហើយមានបណ្តុំរោមពណ៌សមួយដុំលាតសន្ធឹងនៅលើភ្នែក។ ប្រអប់ជើងរបស់វាធំហើយបាតជើងវារលោង ក្រញាំធំ កោងហើយស្រួច។

**ទីជម្រក**

ព្រៃត្រូពិចក្នុងតំបន់អាស៊ីអាគ្នេយ៍ មានដូចជាព្រៃស្រោង ព្រៃរងទឹកភ្លៀង ព្រៃតំបន់ភ្នំ និងព្រៃតំបន់ដីសើម។

**ការគំរាមកំហែង**

ការបរបាញ់យកថង់ប្រមាត់និងសំណាករបស់វាសម្រាប់ប្រើប្រាស់ជាឱសថបុរាណ ការជួញដូរធ្វើជាសត្វចិញ្ចឹម។ ការកាប់ឈើនិងការបំផ្លាញទីជម្រកក៏ជាការគំរាមកំហែងដ៏សំខាន់ផងដែរ។

**របៀយរស់នៅ**

ប្រទេសកម្ពុជា បង់ក្លាដែស ព្រុយណេ ចិន ឥណ្ឌា ឥណ្ឌូនេស៊ី លាវ ម៉ាឡេស៊ី ភូមា ថៃឡង់និង វៀតណាម។

**របបអាហារ**

សព្វាសីៈ ចំណីចម្បងរបស់វាគឺកណ្តៀរ ស្រមោច កូនកញ្ចៃ កូនឃ្មុំ ទឹកឃ្មុំ និងផ្លែឈើជាច្រើនប្រភេទ។

NE DD LC > NT VU EN CR EW EX

LEAST CONCERN

RED LIST

# ជ្រូកព្រៃ

## Wild Boar

## *Sus scrofa*



**ភិនភាគ**

ជ្រូកព្រៃមានរោមខ្លួនពីរស្រទាប់ហើយក្រាស់។ រោមប្រែងនៅស្រទាប់ខាងលើក្រាស់ហើយរឹង រោមខ្លួននៅផ្នែកខាងក្រោមទន់ជាង។ វាមានភ្នែកតូចៗ ប៉ុន្តែមានច្រមុះវែងស្រួច។

**ទីជម្រក**

វារស់នៅក្នុងជម្រកខុសៗគ្នា មានដូចជា ព្រៃតំបន់ត្រូពិច វាលស្មៅ ប៉ុន្តែពួកវាចូលចិត្តព្រៃរបោះជាងគេ។

**ការគំរាមកំហែង**

ការបាត់បង់ទីជម្រកនិងការប្រមាញ់យកសាច់ជាអាហារ។

**របៀបរស់នៅ**

មានវត្តមានពាសពេញទ្វីបអឺរ៉ុបនិងអាស៊ី

**របបអាហារ**

សព្វាសីៈ ភាគច្រើនស៊ីរុក្ខជាតិ ផ្លែឈើ ឫសឈើ ដំណាំកសិផល។ ពួកវាក៏ស៊ីពងសត្វ សាកសព សត្វកកេរតូចៗ សត្វល្អិតនិងដង្កូវផងដែរ។

NE DD LC NT VU EN ENDANGERED CR EW EX

# ទន្សោង

## Banteng
## *Bos javanicus*



**ភិនភាគ**

ទន្សោងឈ្មោលមានសម្បុរក្រហមក្រមៅ ឬ ឈាមជ្រូកចាស់។ ញីនៅក្មេងមានសម្បុរឈាមជ្រូកហើយមានឆ្នូតខ្នងពណ៌ខ្មៅ។ ទាំងពីរភេទមានស្នាប់ជើងផ្នែកខាងក្រោមពណ៌ស ត្រគាកពណ៌ស ច្រមុះនិងមាត់ពណ៌សហើយនៅលើភ្នែកមានអុចៗពណ៌សផងដែរ។

**ទីជម្រក**

ព្រៃរបោះវាលហើយស្ងួត ព្រៃរងទឹកភ្លៀងតំបន់ត្រូពិចនិងព្រៃលិចទឹកតាមរដូវកាល។ ពួកវាក៏រស់នៅតាមវាលស្មៅ ចំការឈើធំៗនិងតំបន់កសិកម្មដែលគេបោះបង់ចោល។

**ការគំរាមកំហែង**

ការបាត់បង់ទីជម្រក ការបរបាញ់យកសាច់ ស្នែងនិងយកគ្រោងក្បាលជាគ្រឿងជ័យភណ្ឌ ការកាត់ពូជជាមួយសត្វស្រុកនិងការឆ្លងជំងឺពីសត្វស្រុក (ដូចជា គោក្របីជាដើម)។

**របាយរស់នៅ**

ប្រទេសកម្ពុជា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ភូមា ថៃឡង់ដ៍ និងវៀតណាម។

**របបអាហារ**

តិណាសីៈ ស៊ីស្មៅ ឬស្សី ផ្លែឈើ ស្លឹកឈើនិងមែកឈើខ្ចីៗ។

# ខ្ទីង

# Gaur

# *Bos gaurus*

NE DD LC NT **VU** VULNERABLE EN CR EW EX



**ភិនភាគ**

ខ្ទីងមានក្បាលធំ ដងខ្លួនវែង ជើងរឹងមាំ។ ខ្លួនរបស់វាមានសម្បុរចម្រុះពណ៌ចាប់ពីក្រហមព្រឿងៗ ឬ ត្នោត រហូតដល់ពណ៌ខ្មៅ ហើយជើងរបស់វាមានពណ៌ព្រលែត។ ទាំងពីរភេទមានស្នែងកោងឡើងលើ។ ស្នែងរបស់វាមានគល់ពណ៌លឿង ហើយចុងស្នែងពណ៌ខ្មៅ។ ខ្ទីងមានបូកនៅលើស្មារបស់វា ជាពិសេសសត្វឈ្មោលមានបូកក្រាស់ខ្ពស់។ ពួកវាមានបួរលាតសន្ធឹងពីកដល់ជើងមុខរបស់វា។

**ទីជម្រក**

ព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង ព្រៃរបោះដីសើមនិងព្រៃរបោះស្ងួត។

**ការគំរាមកំហែង**

ការបាត់បង់ទីជម្រក ការបរបាញ់យកសាច់ ស្នែងនិងយកគ្រោងក្បាលជាគ្រឿងជ័យភណ្ឌ ការកាត់ពូជជាមួយសត្វស្រុកនិងការឆ្លងជំងឺពីសត្វស្រុក (ដូចជា គោក្របីជាដើម)។

**របបអាហារ**

ជាពួកតិណាសី ចំណីរបស់វាគឺល្បះខ្ទី ស្លឹកឈើព្រៃ ទំពាំង រល្លី និងស្មៅស្ងួតៗ។

**រប៉ាយរស់នៅ**

ប្រទេសកម្ពុជា ប៊ូតាន់ ចិន ឥណ្ឌា លាវ ម៉ាលេស៊ី ភូមា នេប៉ាល់ ថៃឡង់និងវៀតណាម។

# ឈ្លូស

## Northern Red Muntjac
*Muntiacus vaginalis*

NE DD **LC** LEAST CONCERN NT VU EN CR EW EX



**រូបភាគ**

ឈ្លូសឈ្មោលមានស្នែងតូចត្រង់។ ញីគ្មានស្នែងទេ គឺគ្រាន់តែមានលេចចេញជាដុំពកឆ្អឹងតូចនៅពីលើក្បាលជាមួយនឹងរោមកញ្ចុំប៉ុណ្ណោះ។ ទាំងពីរភេទមានចៃដូចគ្នា ប៉ុន្តែឈ្មោលមានចៃវែងជាងញី។ វាមានរោមពណ៌ត្នោត-លឿង ដោយមានពណ៌រាងស្រគាំនៅផ្នែកខាងលើ ហើយព្រលែតនៅផ្នែកខាងក្រោម។

**ទីជម្រក**

ឈ្លូសរស់នៅតាមជម្រកច្រើនសណ្ឋានក្នុងព្រៃនិងព្រៃគម្ពោត មានដូចជាវាលទំនាប តំបន់ភ្នំ ព្រៃក្រាស់ៗនិងព្រៃតំបន់វាល ព្រៃស្រោង ព្រៃរបោះ ព្រៃដុះឡើងវិញនិងវាលស្មៅ តំបន់កសិកម្មក្បែរព្រៃ។

**ការគំរាមកំហែង**

ការបាត់បង់ទីជម្រក ការបរបាញ់យកសាច់ ស្នែងនិងយកគ្រោងក្បាលជាគ្រឿងលម្អ។

**របាយរស់នៅ**

វាមានវត្តមានពាសពេញអាស៊ីអាគ្នេយ៍និងអាស៊ីខាងត្បូង។

**របបអាហារ**

តិណាសីៈ ស៊ីស្លឹកឈើ ស្មៅ តិណទេស ផ្លែឈើ គ្រាប់ធុញ្ញជាតិ ពន្លករុក្ខជាតិ ពងសត្វនិងសត្វតូចៗ។

| NE | DD | LC | NT | VU VULNERABLE | EN | CR | EW | EX |
|---|---|---|---|---|---|---|---|---|

# ប្រើសស្បូវ

## Sambar Deer

## *Rusa unicolor*



**រូបរាង** ប្រទេសកម្ពុជា បង់ក្លាដែស ប៊ូតាន់ ព្រុយណេ ចិន ឥណ្ឌា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី លាវនិងភូមា។

**ភិនភាគ** សម្បុរត្នោតខ្ចី ឬ ចាស់ ទៅប្រផេះ ឬ លឿង ហើយនៅផ្នែកខាងក្រោមមានពណ៌រាងព្រលែត។ ឈ្មោលមានស្នែងធំ រឹង ដែលមានខ្នែងខាងចុង៣។ កន្ទុយវែងជាទូទៅមានពណ៌ខ្មៅនៅផ្នែកខាងលើ ហើយមានពណ៌សស្រអាប់ ឬ ស នៅផ្នែកខាងក្រោម។ ជើងវែងហើយមាំ ផ្នែកខាងលើមានពណ៌ត្នោតចាស់ ហើយជើងផ្នែកខាងក្នុងមានពណ៌ព្រលែត ឬ សស្រអាប់ ត្រចៀកវែងរបស់វាមានពណ៌ប្រផេះត្នោត។

**ទីជម្រក** អាចសម្របខ្លួនទៅតាមជម្រកផ្សេងៗជាច្រើនប្រភេទ ចាប់ពីព្រៃស្រោង តំបន់ទំនាប វាលស្មៅ តំបន់ដីសើមនិងតំបន់ព្រៃផ្សេងទៀតដូចជា ព្រៃមានសំណើមខ្ពស់ ព្រៃរបោះ ព្រៃស្រោងនិងព្រៃពាក់កណ្ដាលស្រោង។

**ការគំរាមកំហែង** ការបរបាញ់និងការរានទន្រ្ទានព្រៃ ដាទីជម្រករបស់វា។

**របបអាហារ** តិណាសីៈ ស៊ីស្មៅច្រើនប្រភេទ មែកឈើ ស្លឹកឈើ ផ្លែឈើ រុក្ខជាតិទឹក តិណទេស ពន្លកឈើ ផ្លែឈើតូចៗ ឫសឈើនិងសំបកឈើ។ ពួកវាក៏ស៊ីរុក្ខជាតិនៅព្រៃគម្ពោតនិងដើមឈើតូចៗផងដែរ។

NE DD LC NT VU EN ENDANGERED CR EW EX

# ក្ដាន់

## Hog Deer

## *Axis porcinus*



**ភិនភាគ**

ក្ដាន់មានខ្លួនមូល ជើងខ្លី ជើងក្រោយខ្ពស់ជាងមុខ ហើយមានចុងកន្ទុយពណ៌ស។ ឈ្មោលមានមាឌធំជាងញី ហើយកក្រាស់ជាង។ ញីសម្បុរក្រហមត្នោតនៅរដូវក្ដៅ ប្រែពណ៌ជាស្រអាប់នៅរដូវត្រជាក់។ ឈ្មោលពណ៌ត្នោតចាស់ក្នុងរដូវបន្ដពូជ។

**ទីជម្រក**

វាលទំនាបនិងវាលស្មៅដីសើម ជើងភ្នំ តាមជួរភ្នំហិមាល័យ ចាប់ពីប្រទេសប៉ាគីស្ថាន រហូតដល់ប្រទេសកម្ពុជា។ ក្ដាន់មិនចូលចិត្តព្រៃក្រាស់និងតំបន់កសិកម្មទេ។

**ការគំរាមកំហែង**

ការដាក់អន្ទាក់និងការបរបាញ់យកសាច់ ការបាត់បង់ទីជម្រកនិងការរានទន្រ្ទានយកដីធ្វើកសិកម្មផ្សេងៗ។

**របាយរស់នៅ**

ប្រទេសកម្ពុជា បង់ក្លាដែស ប៊ូតាន់  ឥណ្ឌា នេប៉ាល់ ប៉ាគីស្ថាន ចិន លាវ ភូមា ថៃឡង់ដ៍និងវៀតណាម។

**របបអាហារ**

ក្ដាន់ជាប្រភេទសត្វស៊ីស្មៅជាអាហារ ចំណីដ៏ចម្បងរបស់វាគឺស្មៅ ចំណីបន្ទាប់បន្សំមានដូចជា រុក្ខជាតិនិងស្លឹកឈើផ្សេងៗ។

NE DD LC LEAST CONCERN NT VU EN CR EW EX

# ក្តាន់ញ៉ៀងតូច ឬ ផ្ទងតូច

**Lesser Mousedeer**

***Tragulus Kanchil***



**ភិនភាគ**

ក្តាន់ញ៉ៀងតូចគ្មានស្នែងទេ ឈ្មោលពេញវ័យមានចៃវែងដុះនៅផ្នែកខាងលើនៃក្រអូមមាត់ ហើយលយចេញមកខាងក្រៅតាមចំហៀងមាត់។ វាគ្មានធ្មេញលើជួរមុខទេ។ រោមរបស់វាមានពណ៌ត្នោតលាយជាមួយពណ៌ទឹកក្រូចតិចៗ។

**ទីជម្រក**

ពួកវាមានវត្តមាននៅតាមព្រៃព្រហ្មចារីនិងព្រៃដុះឡើងវិញដែលជាប្រភេទព្រៃលូតលាស់លឿន។ ពួកវាតែងតែរស់នៅតាមក្រហែងថ្ម រន្ធឈើ និងសារពើរុក្ខជាតិក្រាស់ៗនៅក្បែរទឹក។

**ការគំរាមកំហែង**

ការកាប់បំផ្លាញព្រៃឈើនិងការបរបាញ់យកសាច់ជាអាហារ។

**របាយរស់នៅ**

តំបន់ព្រៃត្រូពិចនៅអាស៊ីអាគ្នេយ៍។

**របបអាហារ**

ជាពួកតិណាសី: ស៊ីស្លឹកឈើ ពន្លកឈើ រុក្ខជាតិតូចៗនិងផ្លែឈើជ្រុះ។

# រមាំង

## Eld's Deer
## *Rucervus eldii*

NE | DD | LC | NT | VU | EN ENDANGERED | CR | EW | EX




**ភិនភាគ**

ជើងរាងរៀវវែងសមនឹងដងខ្លួនទ្រវែង ហើយកស្តួច ក្បាលធំ។ រោមខ្លួនរាងគ្រើមប្រែប្រួលពីពណ៌ក្រហម-ត្នោត (រដូវក្តៅ) ទៅជាពណ៌ត្នោតចាស់ (រដូវរងា)។ ឈ្មោលមានស្នែងរាងកោងឡើងលើទម្រង់ដូចជាដងពិណ្យ នៅជុំវិញករបស់វាគ្របដណ្តប់ទៅដោយរោមក្រាស់ហើយវែង។

**ទីជម្រក**

ព្រៃរបោះ វាលស្មៅ ពួកវាចូលចិត្តរស់នៅតាមតំបន់ក្បែរទឹក។

**ការគំរាមកំហែង**

ការបរបាញ់យកសាច់ ការបាត់បង់ទីជម្រកនិងការបាត់បង់ជងព្រៃភ្ជាប់តំបន់ព្រៃមួយកន្លែងទៅព្រៃមួយកន្លែងទៀត។

**របាយរស់នៅ**

ប្រទេសកម្ពុជា ចិន លាវ ថៃឡង់ដ៍និងវៀតណាម។

**របបអាហារ**

ស្មៅនិងក្រុមរុក្ខជាតិតូចៗជាចំណីចម្បងរបស់រមាំង រួមមានស្មៅច្រើនប្រភេទ ផ្លែឈើ បន្លែស្រស់ៗ ព្រមទាំងរុក្ខជាតិតំបន់ដីសើម។

# ខ្លាធំ ឬ ខ្លាដំបង

## Tiger

## *Panthera tigris*

NE DD LC NT VU EN ENDANGERED CR EW EX



**រោមខ្លួន** ... 

| | |
|---|---|
| រូបរាង | រោមខ្លួនពណ៌ក្រហមលឿង ហើយមានឆ្នូតបង្អង់ពណ៌ខ្មៅរត់ទទឹងដងខ្លួន នៅលើស្មានិងត្រគាក ដែលមានទំហំខុសៗគ្នា ចន្លោះមិនប៉ុនគ្នានិងប្រវែងខុសៗគ្នា។ ប្រមុះនិងមាត់ បំពង់ក ដើមទ្រូង ពោះនិងផ្នែកខាងក្រោមនៃដៃជើងរបស់វាពណ៌ស ឬ ស្លេក។ នៅលើភ្នែកមានពណ៌សសន្ធឹងមកដល់ថ្ពាល់។ ខាងក្រោយទងត្រចៀកមានពណ៌សដុបៗ។ កន្ទុយរបស់វាពណ៌ក្រហមលឿង ព័ទ្ធជុំវិញទៅដោយវណ្ណកន្ទុយពណ៌ខ្មៅជាច្រើន។ |
| ទីជម្រក | ភាគច្រើនខ្លាធំមានវត្តមាននៅតាមព្រៃត្រូពិចក្នុងទ្វីបអាស៊ី ទោះបីជាពួកវាធ្លាប់មានប្រវត្តរស់នៅពាសពេញតំបន់ដែលមានអាកាសធាតុក្តៅជាង ឬត្រជាក់ជាងអាស៊ីយ៉ាងណាក៏ដោយ។ |
| ការគំរាមកំហែង | ការបរបាញ់ ការបាត់បង់ទីជម្រកនិងការថយចុះនូវចំនួនសត្វពាហនៈដែលចំណីរបស់វា។ |
| របបអាហារ | មំសាសីៈ សត្វពាហនៈធំៗ ខ្លាឃ្មុំនិងសត្វតូចៗ។ ប្រសិនបើគ្មានចំណីទាំងនោះទេ ពួកវាស៊ីសត្វស្លាប ល្មូន ត្រីនិងសត្វពាហនៈតូចៗ។ |
| រប៉ាយរស់នៅ | ប្រទេសបង់ក្លាដែស ប៊ូតាន់ ចិន ឥណ្ឌា ឥណ្ឌូនេស៊ី លាវ ម៉ាឡេស៊ី ភូមា នេប៉ាល់ រុស្ស៊ី ថៃឡង់ដ៍។ ប្រហែលជាផុតពូជនៅកម្ពុជា កូរ៉េនិងវៀតណាម។ |

# ពង្រូល

## Sunda Pangolin
## *Manis javanica*

NE DD LC NT VU EN **CR** CRITICALLY ENDANGERED EW EX



**ភិនភាគ**

ពង្រូលមានកន្ទុយដែលអាចថ្លក់តោងឡើងដើមឈើបាន។ ខ្លួនរបស់វាគ្របដណ្តប់ដោយស្រកាត់ជាជួរនិងរោមដូចជាសរសៃ។ ស្រកានៅផ្នែកខាងក្រោយនិងនៅសងខាងពណ៌ត្នោតភ្លារទៅលឿង។ រោមពោះនិងមុខពណ៌ស ទៅត្នោតព្រលែត។ ពង្រូលជាសត្វដែលមានក្រញ៉ាំរឹងមាំហើយខ្លាំង តែគ្មានធ្មេញទេ។

**ទីជម្រក**

ពួកវារស់នៅតាមព្រៃព្រហ្មចារីនិងព្រៃដុះឡើងវិញ រួមមានព្រៃរបោះ និងតំបន់កសិកម្ម។

**ការគំរាមកំហែង**

ការបរបាញ់និងការទាក់ចាប់ច្រើនហួសប្រមាណ ដោយមធ្យោបាយទាំងពីរ (មានតម្រុយទុកមុននិងគ្មានតម្រុយទុកមុន) ដើម្បីជួញដូរក្នុងទីផ្សារខុសច្បាប់ (ក្នុងស្រុកនិងក្រៅស្រុក) សម្រាប់ផ្គត់ផ្គង់ដល់ការប្រើប្រាស់របស់មនុស្សនិងធ្វើជាឱសថបុរាណ។

**របាយរស់នៅ**

ប្រទេសកម្ពុជា ព្រុយណេ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី លាវ ភូមា សិង្ហបុរី ថៃឡង់និងវៀតណាម។

**របបអាហារ**

ស្រមោចនិងកណ្តៀរ។

# ដំរីអាស៊ី

## Asian Elephant

## *Elephas maximus*

NE DD LC NT VU < EN > CR EW EX

ENDANGERED

RED LIST



**ភិនភាគ**

ស្បែករបស់វាក្រាស់ពណ៌ប្រផេះ ឬ ត្នោត គ្របដណ្ដប់ដោយរោមរឹងៗ។ នៅផ្នែកខាងចុងនៃប្រមោយរបស់វាមានសណ្ឋានដូចជាចង្អុលដៃ។ ជើងមុខនីមួយៗមានក្រចក៥ ហើយជើងក្រោយនីមួយៗមានក្រចកតែ៤ទេ។ ឈ្មោលពេញវ័យធំជាងញីហើយឈ្មោលមានភ្លុកពីរ ប៉ុន្តែញីគ្មានភ្លុកទេ។

**ទីជម្រក**

វាលស្មៅ ព្រៃស្រោងតំបន់ត្រូពិច ព្រៃពាក់កណ្ដាលស្រោង ព្រៃរបោះសើម ព្រៃរបោះស្ងួតនិងព្រៃបន្លាស្ងួត។ លើសពីនេះទៅទៀតវារស់នៅតាមចំការ ព្រៃឈើនិងព្រៃដុះឡើងវិញ ឬ ព្រៃគុម្ពោត។

**ការគំរាមកំហែង**

ការបាត់បង់ទីជម្រកនិងការបាត់បង់ដងព្រៃតភ្ជាប់ពីតំបន់ព្រៃមួយទៅតំបន់ព្រៃមួយផ្សេងទៀត ការប្រទាំងគ្នារវាងមនុស្សនិងដំរី និងការទាក់ចាប់ ព្រមទាំងការជួញដូរដំរីខុសច្បាប់។

**របៀបរស់នៅ**

ប្រទេសកម្ពុជា បង់ក្លាដែស ប៊ូតាន់ ចិន ឥណ្ឌូនេស៊ី លាវ ម៉ាឡេស៊ី ភូមា នេប៉ាល់ ស្រីលង្កា ថៃឡង់ និងវៀតណាម។

**របបអាហារ**

ជាពួកតិណាសីដែលស៊ីរុក្ខជាតិជាចំណី។ ចំណីចម្បងជាប្រចាំរបស់វាគឺ ស្មៅ ស្លឹកឈើ ឫសឈើ សំបកឈើនិងគុម្ពោតព្រៃ។

# ផ្សោតក្បាលត្រឡោក

## Irrawaddy Dolphin

## *Orcaella brevirostris*



**ភិនភាគ**

សម្បុរប្រផេះចាស់ ហើយមានពណ៌ប្រផេះស្រាលនៅផ្នែកខាងក្រោមពោះ។ វាមានក្បាលធំ មាំរាងមូលតែគ្មានចំពុះទេ។ វាមានព្រុយទ្រូងធំវែងរាងត្រីកោណដូចជាច្រវា ហើយមានព្រុយខ្នងរាងត្រីកោណសន្ទឹងលើខ្នងប្រហែលជា ៧០% នៃបណ្តោយខ្លួន។

**ទីជម្រក**

តាមទន្លេៈ ក្នុងរណ្តៅទឹកជ្រៅៗ តាមចំណុចប្រសព្វមុខទន្លេ ឬ នៅជិតកន្លែងទឹកហូរខ្លាំង។ តាមតំបន់ឆ្នេរៈ នៅចំណុចប្រសព្វរវាងទឹកប្រៃនិងទឹកសាប។

**ការគំរាមកំហែង**

រងគ្រោះថ្នាក់ដោយសារជាប់ក្នុងឧបករណ៍នេសាទ ហើយលង់ទឹកស្លាប់។ ការបាត់បង់ទីជម្រក ហើយចំនួនតិចរស់នៅរប៉ាត់រប៉ាយដោយសារទំនប់វារីអគ្គីសនី។ មានការកើនឡើងនៃកំទេចកំណាកដោយសារការកាប់បំផ្លាញព្រៃឈើ ព្រមទាំងការរុករករ៉ែមាស ការបូមខ្សាច់ ការបូមក្រួស ជាតិពុល និងការប្រែប្រួលរំហូរទឹកសាប។

**របាយរស់នៅ**

ប្រទេសកម្ពុជា បង់ក្លាដែស ព្រុយណេ ឥណ្ឌា លាវ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ភូមា ហ្វីលីពីន សិង្ហបុរី ថៃឡង់ដ៍ និងវៀតណាម។

**របបអាហារ**

មច្ឆា សិរបាទសត្វ (សត្វមានជើងលើក្បាលដូចជាមឹក) និងសត្វវន្តជាតិ(សត្វទឹកមានសំបករឹងដូចជាក្តាម ខ្យង)។

# អណ្តើកបិទមុខ ឬ អណ្តើកឡឹតមុខ

## Southeast Asian Box Turtle

## *Cuora amboinensis*

NE DD LC NT VU EN ENDANGERED CR EW EX



**រូបរាង**

ស្នូកទ្រូង (បាតស្នូក) របស់វាមានលក្ខណៈជាសន្ទះអាចមូរលោបាន ដែលអនុញ្ញាតឱ្យខ្លួនរបស់វាទាំងមូល(ក្បាលនិងជើង) អាចរួញចូលក្នុងស្នូកហើយបិទជិតបានយ៉ាងងាយ។ អណ្តើកបិទមុខស្នូកខ្មៅ អាចសម្គាល់បានដោយមានឆ្នូតពណ៌លឿងពាជួរនៅលើក្បាល។

**ទីជម្រក**

ច្រើនមានវត្តមាននៅតាមតំបន់ទឹកនឹង ប៉ុន្តែពួកវាក៏អាចរស់នៅតាមតំបន់ទឹកជាច្រើនទៀត លើកលែងតែទន្លេធំៗនិងអាងទឹកធំៗ។

**ការគំរាមកំហែង**

ការប្រមូលច្រើនហួសប្រមាណធ្វើជាអាហារ ការជួញដូរធ្វើជាសត្វចិញ្ចឹម និងធ្វើឱសថបុរាណ។

**រប៉ាយរស់នៅ**

ព្រៃត្រូពិចតាមតំបន់ទំនាបនៅអាស៊ីអាគ្នេយ៍។

**របបអាហារ**

ពួកវាស៊ីរុក្ខជាតិ ផ្លែឈើជ្រុះនិងពួកសត្វឥតឆ្អឹងកងទន់ៗមួយចំនួនដូចជាក្រុមកិមិជាតិ (ជង្កូវ ព្រូន) និងខ្យងឥតសំបក។

# អណ្តើកព្រេច ឬ អណ្តើកភ្នំ

## Elongated Tortoise

## *Indotestudo elongata*

NE | DD | LC | NT | VU | EN | CR CRITICALLY ENDANGERED | EW | EX



**ភិនភាគ**

អណ្តើកព្រេចមានស្នូកខ្នងរាងទ្រវែងពណ៌ត្នោត-លឿង លាយជាមួយពណ៌ខ្មៅនៅផ្នែកកណ្តាលនៃស្រកាស្នូកនីមួយៗរបស់វា។ អណ្តើកព្រេចឈ្មោលពេញវ័យមានស្នូកទ្រូងផតនិងមានកន្ទុយវែង។ ចំណែកឯអណ្តើកញីវិញមានកន្ទុយខ្លី។

**ទីជម្រក**

ប្រភេទព្រៃរបោះ ជាជម្រកដ៏សំខាន់របស់វា។

**ការគំរាមកំហែង**

ក្រៅពីការបាត់បង់ទីជម្រក អណ្តើកព្រេចត្រូវបានគេចាប់យកទៅលក់តាមទីផ្សារសម្រាប់ធ្វើជាអាហារនៅក្នុងប្រទេសជាច្រើន ជាពិសេសនៅប្រទេសវៀតណាមនិងចិន។ វាក៏ត្រូវបានគេចាប់យកមកធ្វើជាឱសថបុរាណនិងលក់ធ្វើជាសត្វចិញ្ចឹមផងដែរ។

**រប៉ាយរស់នៅ**

ក្នុងតំបន់អាស៊ីអាគ្នេយ៍និងអាស៊ីខាងត្បូង

**របបអាហារ**

ចំណីរបស់វាមានច្រើនប្រភេទដូចជាផ្លែឈើ ផ្កា ស្លឹករុក្ខជាតិ ផ្សិតនិងសត្វឥតឆ្អឹងកងខ្លួនទន់ដូចជាជង្កូវជាដើម។




# អណ្តើកស្រែ

## Mekong Snail-eating Turtle

## *Malayemys subtrijuga*



**ភិនភាគ**

អណ្តើកស្រែមានក្បាលធំ ស្នូកពណ៌ត្នោតហើយមានទ្រនុងស្នូកពជួរ ដោយឡែកពីគ្នានៅផ្នែកខាងលើ។ នៅតាមគែមនិងផ្នែកខាងក្រោមស្នូកពណ៌លឿង។ វាមានក្បាលពណ៌ខ្មៅ ហើយមានឆ្នូតពណ៌ស ឬ លឿងចាប់ពីចុងច្រមុះទៅផ្នែកខាងលើភ្នែកនិងផ្នែកខាងក្រោមភ្នែក។ មានឆ្នូតច្រមុះ ៣គូ ភ្នែកខ្មៅ ហើយមានរង្វង់ពណ៌ព្រលែតនៅលើប្រស្រីភ្នែក។

**ទីជម្រក**

អណ្តើកស្រែរស់នៅតាមព្រៃលិចទឹកតាមរដូវកាល និងនៅតាមវាលស្រែ។

**ការគំរាម កំហែង**

ទោហនកម្មសត្វព្រៃច្រើនហួសប្រមាណ សម្រាប់ធ្វើជាអាហារនិងការជួញដូរធ្វើជាសត្វចិញ្ចឹម។

**រប៉ាយ រស់នៅ**

ប្រទេសកម្ពុជា លាវនិងវៀតណាម។ អណ្តើកស្រែប្រហែលជាមានវត្តមាននៅភាគខាងកើតប្រទេសថៃឡង់និងឥណ្ឌូនេស៊ី( កំណត់ត្រាមិនច្បាស់លាស់ )

**របប អាហារ**

ពួកវាស៊ីសាច់ជាអាហារៈ ខ្យង ជន្លេន សត្វវន្តជាតិ ( ក្តាម ) សត្វល្អិតក្នុងទឹកនិងត្រីតូចៗ។




# អណ្តើកសោម

## Giant Asian Pond Turtle
*Heosemys grandis*



**ភិនភាគ**

វាមានស្នូកពណ៌ត្នោតស្រាល ទៅស្រអាប់។ អណ្តើកសោមពេញវ័យនិងនៅក្មេងមានទ្រនុងស្នូកខ្នងពណ៌ព្រលែត។ ក្បាលធំមាំពណ៌ត្នោត-លឿង (ពណ៌សូកូឡា) ហើយច្រមុះរបស់វារលីង។ នៅសងខាងក្បាលនិងក មានស្នាមអុជៗ។

**ទីជម្រក**

អណ្តើកសោមរស់នៅក្នុងតំបន់ទឹកនឹងដូចជាត្រពាំង ទន្លេនិងបឹងដែលមានទឹកហូរយឺតៗក្នុងព្រៃលិចទឹកតាមរដូវកាល។

**ការគំរាមកំហែង**

ការចាប់ដោយខុសច្បាប់និងការជួញដូរខុសច្បាប់នៅតំបន់ជាច្រើនក្នុងទ្វីបអាស៊ី។

**របបអាហារ**

សព្វាសីៈ ចំណីរបស់វាមានដូចជារុក្ខជាតិដែលដុះក្នុងទឹកនិងរុក្ខជាតិដែលដុះលើគោក ព្រមទាំងដង្កូវ សត្វល្អិតតូចៗទើបនឹងញាស់ ពួកសត្វល្អិតនិងពួកត្រី។

**របាយរស់នៅ**

ប្រទេសកម្ពុជា លាវ ម៉ាឡេស៊ី ភូមា ថៃឡង់ដ៍ និងវៀតណាម។

NE DD LC NT VU EN CR CRITICALLY ENDANGERED EW EX

# អណ្តើកសង្កល់ ឬ អណ្តើកក្របីក្បាលលឿង

## Yellow-headed Temple Turtle

## *Heosemys annandalii*



**ភិនភាគ**

ស្នូកខ្នងមាំរាងក្រឡូមពណ៌ប្រផេះចាស់ ឬ ខ្មៅរលើបហើយរលោង។ បាតស្នូករបស់វាពណ៌លឿង ឬ ទឹកក្រូច ហើយមានស្នាមដាំលើស្នូកពណ៌ខ្មៅ។ ថ្ងាស ថ្គាមនិងកពណ៌លឿង ដោយមានវ័ណ្ឌពណ៌រាងស្រអាប់បន្តិចហើយថ្គាមលើទាំងពីររបស់វាលយចេញ សំយុងចុះក្រោមរាងស្រួច មុត (សណ្ឋានដូចធ្មេញ)។ ប្រអប់ជើងរបស់វាធំ ដែលមានម្រាមត្បាញជាប់គ្នាយ៉ាងរឹងមាំ។

**ទីជម្រក**

អណ្តើកសង្កល់រស់នៅក្នុងតំបន់ដីសើម តំបន់លិចទឹក ព្រៃមានសំណើមនិងវាលភក់។

**ការគំរាមកំហែង**

ទោហនកម្មសត្វព្រៃច្រើនហួសប្រមាណ ដើម្បីជួញដូរធ្វើជាអាហារនិងធ្វើឱសថបុរាណ ព្រមទាំងការបាត់បង់ទីជម្រក។

**របៀបរស់នៅ**

ប្រទេសកម្ពុជា លាវ ម៉ាឡេស៊ី ថៃឡង់ដ៍ និងវៀតណាម។

**របបអាហារ**

ចំណីរបស់វាភាគច្រើនគឺរុក្ខជាតិដែលដុះក្នុងទឹក បន្ថែមលើនេះទៀតគឺផ្លែឈើជ្រុះ ពេលដែលអាចរកបាន។

# អណ្ដើកហ្លួង ឬ អណ្ដើកសរសៃ

## Southern River Terrapin

## *Batagur affinis*

NE | DD | LC | NT | VU | EN | CR CRITICALLY ENDANGERED | EW | EX



**ភិនភាគ** ជាអណ្ដើកមាឌធំ ក្បាលតូច ចុងច្រមុះងឡើងលើ។ ប្រអប់ជើងរបស់វាមានម្រាម៤ ហើយមានស្បែកជាប់ប្រទាក់គ្នាពីម្រាមមួយទៅម្រាមមួយទៀត។ អណ្ដើកហ្លួងមានលក្ខណៈសម្គាល់និងសម្បុរខុសគ្នា រវាងញីនិងឈ្មោល។ ខណៈដែលញីមិនប្រែប្រួលពណ៌ពេញមួយឆ្នាំ តែឈ្មោលប្រែប្រួលពណ៌ទៅជាខ្មៅខ្លាំងក្នុងរដូវបន្តពូជ (ពណ៌ប្រផេះចាស់ ឬ ខ្មៅ)។ លើសពីនេះទៅទៀត ឈ្មោលមានភ្នែកពណ៌មាសលាយលឿង។

**ទីជម្រក** ដៃសមុទ្រ ព្រៃកោងកាងតាមស្ទឹងតូចៗ ទន្លេទឹករាក់ៗនិងបឹងទឹកប្រៃក្បែរមាត់សមុទ្រ។ ជាទូទៅវារស់នៅក្នុងតំបន់ដែលទទួលឥទ្ធិពលទឹកជោរនាច ប៉ុន្តែវាក៏អាចមានវត្តមាននៅទីតាំងដែលឆ្ងាយពីច្រាំងទន្លេផងដែរ។

**ការគំរាមកំហែង** ការបំផ្លាញទីជម្រក បរិវត្តន៍ទីជម្រក ការបូមខ្សាច់និងការសាងសង់ទំនប់វារីអគ្គីសនី ទោហនកម្មសត្វព្រៃច្រើនហួសប្រមាណដើម្បីយកពងនិងសាច់ធ្វើជាអាហារ។

**របបអាហារ** ជាពួកសព្វាសី ប៉ុន្តែភាគច្រើនអណ្ដើកហ្លួងស៊ីរុក្ខជាតិនិងផ្លែឈើ។

**រប៉ាយរស់នៅ** ប្រទេសកម្ពុជា ឥណ្ឌូនេស៊ី (កោះស៊ូម៉ាត្រា) ម៉ាឡេស៊ី (កោះផេននីស៊ូលា) និងថៃឡងដ៍។

# កន្ធាយក្បាលកង្កែប ឬ ល្មេច

## Asian Giant Softshell Turtle

## *Pelochelys cantorii*

NE DD LC NT VU EN **CR** CRITICALLY ENDANGERED EW EX



**ភិនភាគ**

ក្បាលធំ ប៉ុន្តែភ្នែកតូចៗនៅក្បែរចុងច្រមុះ មើលទៅដូចជាក្បាលកង្កែប ដូច្នោះហើយបានជាគេឱ្យឈ្មោះជាភាសាខ្មែរថា (កន្ធាយក្បាលកង្កែប)។ វាមានស្នូកទន់ហើយរលោងពណ៌អូលីវ។ ពេលមិនទាន់ពេញវ័យ វាមានស្នាមអុជៗពណ៌រាងស្រអាប់នៅលើស្នូកនិងក្បាល ហើយមានពណ៌លឿងនៅជុំវិញស្នូក។

**ទីជម្រក**

វារស់នៅក្នុងទឹកតាមតំបន់ទំនាបខុសៗគ្នាមានដូចជា ទន្លេ ស្ទឹង វាលភក់ និងដែសមុទ្រ។

**ការគំរាមកំហែង**

ការបំផ្លាញទីជម្រក ទោហនកម្មសត្វព្រៃច្រើនហួសប្រមាណតាមតម្រូវការប្រើប្រាស់របស់មនុស្សនិងយកសាច់ធ្វើជាអាហារ ហើយទំនងជាត្រូវបានអ្នកស្ទូចត្រីនិងប្រជានេសាទ សម្លាប់បន្ទាប់ពីជាប់នឹងឧបករណ៍នេសាទ។

**របបអាហារ**

សព្វាសីៈ ចំណីរបស់វាមានដូចជា សត្វវន្តជាតិ (ក្តាម) សិប្បីជាតិ (ខ្យង ខ្ចៅ គ្រុំ លៀស) និងត្រី លើសពីនេះទៅទៀត គឺរុក្ខជាតិ។

**រប៉ាយរស់នៅ**

ប្រទេសកម្ពុជា បង់ក្លាដែស ចិន ឥណ្ឌា ឥណ្ឌូនេស៊ី លាវ ម៉ាលេស៊ី ភូមា ប៉ាពូញូវគីនី ហ្វីលីពីន ថៃឡង់ និងវៀតណាម។

# កន្ធាយអាស៊ី

## Southeast Asian Softshell Turtle
## Amyda Ornata

NE DD LC NT **VU** VULNERABLE EN CR EW EX



**ភិនភាគ**

ស្នូកស្បែកសំប៉ែតរាងពងក្រពើ។ វាមានកវែង ក្បាលរៀវស្តួច ហើយច្រមុះរៀវរាងទ្រវែង។ ជើងរបស់វានីមួយៗមានម្រាមបី ហើយមានទម្រង់ដូចជាច្រវា ដោយមានស្បែកជាប់ប្រទាក់គ្នាពីម្រាមមួយទៅម្រាមមួយទៀត។ ស្នូករបស់វាមានពណ៌ឆ្លាស់គ្នា ចាប់ពីពណ៌ត្នោតលាយម្ទេសទុំ ដល់ពណ៌ប្រផេះលាយពណ៌អូលីវ។

**ទីជម្រក**

ព្រៃតំបន់ត្រូពិច ព្រៃរងទឹកភ្លៀងនិងព្រៃតំបន់ដីសើម ( ទន្លេ បឹង ស្ទឹង និងព្រែក )

**ការគំរាមកំហែង**

ទោហនកម្មសត្វព្រៃច្រើនហួសប្រមាណនៅប្រទេសកម្ពុជា ឡាវ និងវៀតណាម។ ការបាត់បង់ទីជម្រកនៅតំបន់ដែលវារស់នៅ ក៏ជាការគំរាមកំហែងមួយដ៏ចម្បងដែរ។

**របាយរស់នៅ**

គ្រប់ប្រទេសទាំងអស់ក្នុងតំបន់អាស៊ីអាគ្នេយ៍ លើកលែងតែប្រទេសហ្វីលីពីន។

**របបអាហារ**

កន្ធាយអាស៊ីស៊ីចំណីច្រើនយ៉ាង មានដូចជាសត្វល្អិត សត្វវន្តជាតិ ( ក្តាម ) សិប្បីជាតិ ( ខ្យង ) ត្រី រុក្ខជាតិ និងសាច់សាកសពស្អុយ។

# ពស់ថ្លាន់តូច ឬ ពោះថ្លាន់ក្បាលខ្មៅ

NE DD LC NT VU VULNERABLE EN CR EW EX

## Burmese Python
## *Python bivittatus*



**ភិនភាគ**

មានប្រវែងវែងរហូតដល់ទៅ ៦០០ ស.ម មាឧធំ ក្បាលមានរាងត្រីកោណ (ខុសគ្នាពីករាងមូល)។ ក្បាលពណ៌ត្នោតមានសណ្ឋានដូចសញ្ញាព្រួញ ពណ៌ស្លេក និងស្នាមអុជៗពណ៌ត្នោតចាស់នៅលើខ្នង។ ផ្នែកខាងក្រោម (ពោះ) ពណ៌ទឹកដោះគោខាប់ ស ឬ ប្រផេះ។ ពស់ថ្លាន់តូចគ្មានពិសទេ!

**ទីជម្រក**

មានវត្តមាននៅតាមតំបន់ព្រៃ មានដូចជាព្រៃកោងកាង ព្រៃរងទឹកភ្លៀង។ វាក៏រស់នៅតាមវាលស្មៅ វាលភក់ ស្ទឹងនិងព្រែក ព្រមទាំងតំបន់ដីសើមបឹងទន្លេសាបនៅប្រទេសកម្ពុជា។

**ការគំរាមកំហែង**

ការជួញដូរខុសច្បាប់ ការធ្វើទោហនកម្មសត្វព្រៃច្រើនហួសប្រមាណសម្រាប់ធ្វើជាអាហារនិងយកស្បែកលក់។

**របបអាហារ**

ពស់ថ្លាន់តូចជាពួកមំសាសី វាស៊ីថនិកសត្វតូចៗនិងបក្សីសត្វ។

**រប៉ាយរស់នៅ**

ប្រទេសកម្ពុជា បង់ក្លាដែស ចិន ឥណ្ឌា ឥណ្ឌូនេស៊ី លាវ ភូមា នេប៉ាល់ ថៃឡងដ៍និងវៀតណាម។

NE DD LC LEAST CONCERN NT VU EN CR EW EX

# ពស់ថ្លាន់ធំ ឬ ពោះថ្លាន់ក្បាលលឿង

## Reticulated Python

## *Malayopython reticulatus*



មានប្រវែងវែងរហូតដល់ទៅ ៧៧០ស.ម។ ក្បាលពណ៌លឿង ឬ អូលីវ ដែលមានឆ្នូតពណ៌ស្រអាប់ចាប់ពីភ្នែករហូតដល់ចុងថ្គាមនិងមានបន្ទាត់ស្តើងពណ៌ស្រអាប់ចាប់ពីចុងច្រមុះដល់លើក្បាល។ ប្រស្រីភ្នែកពណ៌ទឹកក្រូច ខ្លួនរបស់វាពណ៌ដាំដែង ឬ ត្នោត ហើយនៅតាមដាយមានសណ្ឋានរាងដូចដាំពេជ្រ គ្រោងដូចក្រឡាសំណាញ់ពណ៌រាងស្រអាប់ មានស្នាមអុចៗពណ៌សហើយមានពណ៌ខ្មៅនៅសងខាង។ ពោះរបស់វាពណ៌លឿង។ ពស់ថ្លាន់ធំគ្មានពិសទេ!

**ភិនភាគ**

**ទីជម្រក**

ព្រៃរងទឹកភ្លៀង ចំការព្រៃឈើនិងតំបន់វាលស្មៅ។ វាក៏រស់នៅតាមស្ទឹងតាមទន្លេនិងព្រែកផងដែរ។

**ការគំរាមកំហែង**

ការបរបាញ់យកស្បែក យកសាច់ធ្វើអាហារ ឱសថបុរាណ សត្វចិញ្ចឹម និងការជួញដូរសាច់ពស់។

**របាយរស់នៅ**

ប្រទេសកម្ពុជា បង់ក្លាដែស ឥណ្ឌា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី លាវ ភូមា ហ្វីលីពីន សិង្ហបុរី ថៃឡង់និងវៀតណាម។

**របបអាហារ**

ពស់ថ្លាន់ធំជាពួកមំសាសី វាស៊ីថនិកសត្វតូចៗនិងបក្សីសត្វ។

# អន្សង

## Common Water Monitor
## *Varanus salvator*

NE DD **LC** LEAST CONCERN NT VU EN CR EW EX



**ភិនភាគ**

មាឌធំ ហើយមានប្រវែងវែងរហូតដល់ ២៥០ស.ម។ ដងខ្លួនរឹងមាំជើងធំ ក្រញាំជើងធំ កន្ទុយវែង។ វាមានក្បាលរឹងមាំរាងទ្រវែង ហើយមានរន្ធច្រមុះ ដែលនៅជិតចុងច្រមុះជាងភ្នែក។ ខ្លួនរបស់វាមានសម្បុរប្រផេះហើយមាន ស្នាមអុចៗពណ៌លឿងព្រលែតតម្រៀបគ្នាជារង្វង់ជុំវិញខ្លួន។

**ទីជម្រក**

រស់នៅទាំងក្នុងទឹកនិងលើដីគោក ព្រៃកោងកាង វាលភក់ តំបន់ដីសើម ព្រៃឈើនិងតំបន់ព្រៃគម្ពោត។ ពួកវាក៏មានវត្តមាននៅតាមប្រឡាយ ទីប្រជុំជននិងតំបន់កសិកម្មផងដែរ។

**ការគំរាមកំហែង**

ការបាត់បង់ទីជម្រកនិងការបរបាញ់យកស្បែកធ្វើជំនួញ ធ្វើឱសថបុរាណ និងសម្រាប់ធ្វើជាអាហាររបស់មនុស្ស។

**របាយរស់នៅ**

ប្រទេសកម្ពុជា បង់ក្លាដែស ឥណ្ឌា ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី ភូមា សិង្ហបុរី ស្រីលង្កា ថៃឡង់ដ៍ និងវៀតណាម។

**របបអាហារ**

អន្សងជាពួកមំសាសី វាស៊ីពួកល្អូនច្រើនប្រភេទ ថនិកសត្វ បក្សីសត្វ បាណកសត្វ (សត្វល្អិត) និងពងសត្វ។ លើសពីនេះទៅទៀត វាក៏ស៊ីសាច់សាសពស្អុយផងដែរ។

NE DD LC > NT VU EN CR EW EX
LEAST CONCERN

# ត្រកួត

## Clouded Monitor
*Varanus bengalensis*



**ភិនភាគ**

មាឌធំ(ប៉ុន្តែតូចជាងអន្សង) មានប្រវែងរហូតដល់ ១៦០ ស.ម។ ដងខ្លួនរឹងមាំ ជើងធំ ក្រញាំជើងធំ ហើយកន្ទុយវែង។ វាមានក្បាលរឹងមាំរាងទ្រវែង ហើយមានរន្ធច្រមុះនៅជិតភ្នែកជាងចុងច្រមុះ។ ខ្លួនរបស់វាមានសម្បុរលឿង ឬ ប្រផេះលាយត្នោត ហើយមានស្នាមអុចៗភ្លឺតិចៗ។

**ទីជម្រក**

វាមានវត្តមានតាមជម្រកខុសៗគ្នា ចាប់ពីតំបន់វាលខ្សាច់ រហូតដល់វាលទំនាប តំបន់ព្រៃគម្លោត ក្នុងរយៈកំពស់មិនត្រជាក់ពេក មិនក្តៅពេក។

**ការគំរាមកំហែង**

ការបាត់បង់ទីជម្រកនិងការបរបាញ់យកសាច់ធ្វើជាអាហារ យកស្បែកធ្វើជំនួញនិងធ្វើជាឱសថបុរាណ។

**របៀបរស់នៅ**

ប្រទេសកម្ពុជា អាហ្គានីស្ថាន បង់ក្លាដែស ចិន ឥណ្ឌា ឥណ្ឌូនេស៊ី អ៊ីរ៉ាក់ ស្រីលង្កា ម៉ាឡេស៊ី ភូមា នេប៉ាល់ ឡាវ ប៉ាគីស្ថាន ថៃឡង់និងវៀតណាម។

**របបអាហារ**

ត្រកួតស៊ីសត្វល្អិតជាច្រើនប្រភេទដូចជា ពួកកណ្តូបនិងពួកសត្វកញ្ចៃ (កញ្ចៃ កំពោង កំភេម)។

NE DD LC NT VU **EN** ENDANGERED CR EW EX

# ត្រដក់ធំ

## Greater Adjutant

## *Leptoptilos dubius*



**ភិនភាគ**

កំពស់ប្រមាណ ១៤៥ ទៅ ១៥០ ស.ម ប្រវែងស្លាបទាំងសងខាងប្រហែល ២៥០ ស.ម។ ក្បាលនិងកត្រងោល (គ្មានរោម) ពណ៌ផ្កាឈូកភ្នែកពណ៌ខៀវ រោមលើស្មា ឬ គល់កពណ៌សនិងមានថង់ខ្យល់(ថង់យាម) មួយធ្លាក់ចុះខាងក្រោមក។ ត្រដក់ធំមានស្លាបពណ៌ប្រផេះចាស់ ហើយមានបន្ទះស្លាបខាងចុងពណ៌ប្រផេះស្រាល។

**ទីជម្រក**

តំបន់ដីសើម ព្រៃលិចទឹកតាមរដូវកាល ព្រៃរបោះស្ងួត គំនរសោកសព វាលស្មៅខ្ពស់ៗ ព្រៃកោងកាង តំបន់ទំនាបក្បែរទឹកនិងទីប្រជុំជន (ភូមិភាគឦសាននៃប្រទេសឥណ្ឌា)។

**ការគំរាមកំហែង**

ការបាត់បង់ទីជម្រក ការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតនិងការរំខានផ្សេងៗ។ ការប្រមូលយកពងនិងកូន ការបរបាញ់យកសាច់ធ្វើជាអាហារ។

**របាយរស់នៅ**

ប្រទេសកម្ពុជា ឥណ្ឌា បង់ក្លាដែស នេប៉ាល់ ថៃឡង់ដ៍ និងវៀតណាម។

**របបអាហារ**

ត្រី កង្កែប សត្វល្មូននិងសត្វឥតឆ្អឹងកងធំៗ។ ពួកសត្វកកេរតូចៗនិងសាច់សាកសពស្អុយ។

# ត្រដក់តូច

## Lesser Adjutant

## *Leptoptilos javanicus*

NE DD LC NT **VU** VULNERABLE EN CR EW EX



**ភិនភាគ**

កំពស់ប្រមាណ ១២០ ទៅ ១២៩ ស.ម ប្រវែងស្លាបទាំងសងខាងប្រហែល ២១០ ស.ម។ ក្បាលនិងកត្រងោល (គ្មានរោម)។ ពេលធំពេញវ័យ សងខាងក្បាលរបស់វាពណ៌ក្រហម ឬ ស្វាយ (ក្រហមព្រឿងៗ) ហើយកវាពណ៌លឿង។ ស្លាបផ្នែកខាងលើពណ៌ខ្មៅ ស្លាបផ្នែកខាងក្រោមពណ៌ស។

**ទីជម្រក**

តំបន់ដីសើមបែបធម្មជាតិ ឬ កែច្នៃដោយមនុស្ស  មានទាំងតំបន់វាលនិងតំបន់ព្រៃ។ នៅតំបន់ឆ្នេរភាគច្រើនមានវត្តមានតាមព្រៃកោងកាងនិងតំបន់ទំនាបក្បែរទឹក។ ពួកវាចូលចិត្តតំបន់ដីសើមតូចៗ នៅក្នុងព្រៃរបោះស្ងួតក្នុងទ្វីបអាស៊ី។

**ការគំរាមកំហែង**

ការបាត់បង់ទីជម្រក ការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតនិងការរំខានផ្សេងៗ។ ការប្រមូលយកពងនិងកូន ការបរបាញ់យកសាច់ធ្វើជាអាហារ។

**របបអាហារ**

ត្រដក់តូចស៊ីត្រីជាចំណីចម្បងរបស់វា ប៉ុន្តែវាក៏ស៊ីពួកថលជលិកតូចៗ សត្វវន្តជាតិ (ក្តាម) សិប្បីជាតិ (ខ្យង) ចង្រិតនិងពួកសត្វកកេរតូចៗ។

**រប៉ាយរស់នៅ**

ប្រទេសកម្ពុជា បង់ក្លាដែស ព្រុយណេ ឥណ្ឌា លាវ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ភូមា នេប៉ាល់ ស្រីលង្កា ថៃឡង់ដ៍ និងវៀតណាម។

# ត្រុំ ឬ សត្វកស

## Asian Woollyneck
## *Ciconia episcopus*

NE DD LC < NT > VU EN CR EW EX
NEAR THREATENED



**ភិនភាគ**

សម្បុរខ្លួនរលោងពណ៌ស្វាយ ឬ ខ្មៅ-ខៀវភ្លឺផ្លេក ហើយមានបន្ទួលក្បាលពណ៌ខ្មៅ។ កនិងរោមកញ្ចុំក្រោមកន្ទុយពណ៌ស។ ចំពុះពណ៌ខ្មៅ ហើយមានពណ៌ក្រហមចាស់នៅចុងចំពុះ។

**ទីជម្រក**

តំបន់ដីសើម វាលស្មៅសាវណ្ណានិងតំបន់វាលស្មៅ មានដូចជា ស្ទឹង ព្រែក ទន្លេនិងវាលភក់។ វាក៏រស់នៅតាមជម្រកកែច្នៃដូចជាវាលស្រែជាដើម។

**ការគំរាមកំហែង**

ការបរបាញ់ ការបាត់បង់ទីជម្រក ការបាត់បង់ដងព្រៃតភ្ជាប់ពីតំបន់ព្រៃមួយទៅតំបន់មួយផ្សេងទៀតនិងការបំពុលបរិស្ថាន។

**របបអាហារ**

ត្រី សិប្បីជាតិ ( ខ្យង ខ្ទៅ គ្រុំ លៀស ) សត្វឥតឆ្អឹងកងសមុទ្រ ថលជលិក ពួកសត្វល្មូននិងបាណកសត្វ ( សត្វល្អិត )។

**របាយរស់នៅ**

ក្នុងតំបន់អាស៊ីអាគ្នេយ៍និងអាស៊ីខាងត្បូង

# ក្ងោក

## Green Peafowl
## *Pavo muticus*

NE DD LC NT VU ‹ EN › CR EW EX
ENDANGERED





**ភិនភាគ**

សម្បុរបៃតងភ្លឺផ្លេក ករវែងមានស្នាមអុចៗដូចស្រកាពណ៌ខ្មៅ។ ស្លាបពណ៌រាងស្រអាប់បន្តិច។ ឈ្មោលមានកន្ទុយវែងដៅពណ៌លឿងលាយខៀវ មានលក្ខណៈដូចភ្នែក។ មុខរបស់វាមានឆ្នូតពីរជាន់ ពណ៌សនិងពណ៌ខៀវខ្ចីជុំវិញភ្នែក ជាមួយនឹងបន្ទះពណ៌លឿងរាងដូចចំណិតលោកខែនៅក្បែរត្រចៀកនិងមានបន្ទះពណ៌ត្រីកោណរាងស្រអាប់នៅក្រោមភ្នែក (ពណ៌បៃតងខៀវចំពោះក្ងោកឈ្មោល តែពណ៌ត្នោតចំពោះក្ងោកញី)។

**ទីជម្រក**

ភាគច្រើនរស់នៅក្នុងព្រៃរបោះ មានជង់ស៊ីតេរស់នៅច្រើនបំផុតតាមតំបន់ជិតស្ទឹងនិងតំបន់ដីសើមដែលគ្មានការរំខានពីមនុស្ស។

**ការគំរាមកំហែង**

ការបរបាញ់យកសាច់ជាអាហារនិងស្លាប (កន្ទុយ) ការជួញដូរធ្វើជាសត្វចិញ្ចឹម។ ការប្រមូលយកពងនិងកូន ការបាត់បង់ទីជម្រក។

**របបអាហារ**

ផ្លែឈើ សត្វឥតឆ្អឹងកង ពួកល្អូន កង្កែបនិងពួកសត្វកកេរ។

**រប៉ាយរស់នៅ**

ប្រទេសកម្ពុជា លាវ វៀតណាម ចិន ឥណ្ឌូនេស៊ី ភូមា និងថៃឡង់ដ៍។

NE DD **LC** LEAST CONCERN NT VU EN CR EW EX

# ខ្លែងឆាបលឿងក្រមៅ

## Brahminy Kite

## *Haliastur indus*



**ភិនភាគ**

ជាបក្សីរំពាមានមាឌមធ្យម កន្ទុយកោងខ្លី។ ក្បាលនិងដើមទ្រូងពណ៌ស ហើយផ្នែកផ្សេងទៀតនៃដងខ្លួនរបស់វាមានពណ៌ត្នោតលាយឈាមជ្រូក។ ស្លាបរបស់វាពណ៌ត្នោតលាយឈាមជ្រូក ហើយមានចុងស្លាបពណ៌ខ្មៅ។

**ទីជម្រក**

នៅលើដី (ឆ្ងាយពីសមុទ្រ) និងនៅតាមតំបន់ដីសើមឆ្នេរសមុទ្រ។

**ការគំរាមកំហែង**

ការបរបាញ់និងការប្រមូលកូនតូចៗ ការរំខានពីមនុស្ស ការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតច្រើនពេកនិងការបាត់បង់ទីជម្រក។

**របាយរស់នៅ**

ក្នុងតំបន់អាស៊ីអាគ្នេយ៍និងអាស៊ីខាងត្បូង ភាគខាងជើងនៃប្រទេសអូស្ត្រាលី។

**របបអាហារ**

ពួកវាស្វែងរកចំណី ស៊ីត្រីស្លាប់និងក្ដាមជាអាហារចម្បងរបស់វា ប៉ុន្តែជួនកាលវាក៏ប្រមាញ់ចំណីរស់ ដូចជាថនិកសត្វតូចៗនិងបាណកសត្វ (សត្វល្អិត)។

NE DD LC LEAST CONCERN NT VU EN CR EW EX

## Crested Serpent-eagle
## *Spilornis cheela*



**ភិនភាគ**

ក្បាលធំពណ៌ត្នោតចាស់។ សម្បុរពណ៌ត្នោតដោយមានស្នាមអុចៗពណ៌សភ្លឺ ផ្នែកខាងក្រោមពណ៌ឈាមជ្រូកលាយត្នោត ហើយមានជាយពណ៌រាងស្រអាប់ជាមួយនឹងស្នាមអុចៗពណ៌ស។ ចំពុះពណ៌ខ្មៅ ហើយមានស្បែកមុខនិងភ្នែកពណ៌លឿង។ ជើងនិងម្រាមជើងរបស់វាក៏ពណ៌លឿងដែរ។

**ទីជម្រក**

ព្រៃរបោះស្ងួតនិងសើម ព្រៃកោងកាងនិងព្រៃគម្លោត។

**ការគំរាមកំហែង**

ការគំរាមកំហែងដ៏ចម្បងចំពោះសត្វប្រភេទនេះ មានដូចជាការបំផ្លាញទីជម្រក ការទាក់ចាប់និងការបរបាញ់ខុសច្បាប់។

**របបអាហារ**

សត្វល្មូន (ពស់) បក្សីសត្វតូចៗនិងថនិកសត្វតូចៗ។

**របាយរស់នៅ**

ប្រទេសកម្ពុជា បង់ក្លាដែស ប៊ូតាន់ ព្រុយណេ ចិន ឥណ្ឌា ឥណ្ឌូនេស៊ី ជប៉ុន លាវ ម៉ាឡេស៊ី ភូមា នេប៉ាល់ ប៉ាគីស្ថាន ហ្វីលីពីន ស្រីលង្កា ថៃឡង់ និងវៀតណាម។

# អន្ទាក់ព្រៃច្រើនពណ៌

## Changeable Hawk-eagle
*Nisaetus cirrhatus*

NE DD LC LEAST CONCERN NT VU EN CR EW EX



**រូបភាគ**

សម្បុរពីរពណ៌ផ្លាស់គ្នា (ពណ៌ព្រលែតនិងខ្មៅ)។ ឈ្មោលពណ៌ត្នោតចាស់នៅផ្នែកខាងលើ ទ្រូងនិងពោះពណ៌ស គ្របដណ្តប់ទៅដោយឆ្នូតរាងស្រអាប់ នៅលើភ្លៅមានរោមអង្កន់តូចៗពណ៌ឈាមជ្រូក។ មានពណ៌រាងស្រអាប់នៅពាសពេញផ្នែកខាងលើ ដោយមានពណ៌រាងព្រលែតបន្តិចនៅចុងស្លាប។

**ទីជម្រក**

តំបន់ព្រៃ វាលស្មៅនិងមាត់ព្រៃ ឬ ជាយព្រៃ។

**ការគំរាមកំហែង**

ការគំរាមកំហែងដ៏ចម្បងចំពោះសត្វប្រភេទនេះ មានដូចជាការបំផ្លាញទីជម្រក ការទាក់ចាប់និងការបរបាញ់ខុសច្បាប់។

**របបអាហារ**

ចំណីរបស់វារួមមានបក្សីសត្វដែលមានមាឌប៉ុនមាន់ ថនិកសត្វតូចៗ ពស់និងបង្កួយ ថ្លែន។

**របាយរស់នៅ**

ប្រទេសកម្ពុជា បង់ក្លាដែស ព្រុយណេ ឥណ្ឌា លាវ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី នេប៉ាល់ ហ្វីលីពីន ថៃឡង់ភូមា សិង្ហបុរី ស្រីលង្កានិងវៀតណាម។

NE DD LC LEAST CONCERN NT VU EN CR EW EX

# ខ្លែងស្រាក

## Common Barn-owl

## *Tyto alba*



**ភិនភាគ**

ទម្រង់មុខរាងដូចបេះដូង នៅចន្លោះភ្នែកពណ៌ខ្មៅទាំងពីរ មានកញ្ចុំរោមសំលីទម្រង់ស្រដៀងភ្លុក វែងជាប់នឹងចំពុះពណ៌ផ្កាឈូករបស់វា។ ទ្រូងនិងពោះមានលំដាប់ពណ៌ចាប់ពីស ទៅត្នោត ឬ ត្នោតចាស់ ផ្នែកខាងខ្នងជាធម្មតាមានពណ៌ត្នោតច្រេះ ហើយមានស្នាមអង្កន់ៗនិងស្នាមអុចៗ។

**ទីជម្រក**

វាតែងតែរស់នៅតាមតំបន់វាលលំហដូចជាតំបន់កសិកម្ម ប៉ុន្តែក៏អាចមានវត្តមានតាមទីជម្រកខុសៗគ្នារួមមាន តំបន់អភិវឌ្ឍនិងទីប្រជុំជន។

**ការគំរាមកំហែង**

ការបាត់បង់ទីកន្លែងរកចំណី ការបែកខ្ញែកទីកន្លែងរកចំណី ការធ្វើកសិកម្មតាមបែបប្រពលវប្បកម្ម នគរូបនីយកម្ម ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតនិងការប្រែប្រួលអាកាសធាតុ។

**របាយរស់នៅ**

ក្នុងតំបន់អាស៊ីអាគ្នេយ៍និងអាស៊ីខាងត្បូង អាមេរិកខាងត្បូង ទ្វីបអឺរ៉ុប អាហ្វ្រិកនិងអូស្ត្រាលី។

**របបអាហារ**

ចំណីរបស់វាស្ទើរតែទាំងស្រុងគឺថនិកសត្វតូចៗនិងបក្សីសត្វ។

NE DD LC < NT > NEAR THREATENED VU EN CR EW EX

# សេកសក

## Red-breasted Parakeet
## *Psittacula alexandri*



**កិនភាគ**

សម្បុរបៃតងខ្ចី ទ្រូងពណ៌ផ្កាឈូកចាស់ ក្បាលពណ៌ប្រផេះលាយខៀវ ហើយពុកមាត់និងបំពង់កពណ៌ខ្មៅ។ ឈ្មោលមានចំពុះលើពណ៌ក្រហមភ្លឺ ហើយញីវិញមានចំពុះទាំងមូលពណ៌ខ្មៅ។

**ទីជម្រក**

ចូលចិត្តរស់នៅតាមព្រៃរបោះស្ងួត ព្រៃរបោះសើម ដំណុះព្រៃក្មេង (ព្រៃដុះឡើងវិញ) ព្រៃកោងកាង តំបន់កសិកម្មដែលសំបូរដើមឈើច្រើននិងក្បែរលំនៅដ្ឋានរបស់មនុស្ស។

**ការគំរាមកំហែង**

ការជួញដូរធ្វើជាសត្វចិញ្ចឹមនិងការបាត់បង់ទីជម្រក។

**របាយរស់នៅ**

ប្រទេសកម្ពុជា បង់ក្លាដែស ប៊ូតាន់ ចិន ឥណ្ឌា ភូមា ឥណ្ឌូនេស៊ី លាវ នេប៉ាល់ ថៃឡងដ៍និងវៀតណាម។

**របបអាហារ**

ផ្លែឈើព្រៃនិងផ្លែឈើដំណាំកសិកម្ម ផ្កាព្រៃ ទឹកដម សំបកគ្រាប់ឈើនិងគ្រាប់ឈើ ស្លឹកឈើនិងគ្រាប់ធញ្ញជាតិ មានដូចជាស្រូវនិងពោត។

NE DD LC NT NEAR THREATENED VU EN CR EW EX

# សេកសោម

## Alexandrine Parakeet
## *Palaeornis eupatria*



**ភិនភាគ**

សេកសោមសម្បុរពណ៌បៃតងស្ទើរតែទាំងអស់ ដោយមានបណ្តុំរោមពណ៌ក្រហមនៅលើស្មា ហើយចំពុះក៏ពណ៌ក្រហមដែរ។ សត្វញីគ្មានប្រទ្បៀកទេ តែឈ្មោលមានប្រទ្បៀកតូចស្តើង (ខាងមុខពណ៌ខ្មៅ ហើយនៅក្បែរត្រចៀកពណ៌ផ្កាឈូក)។ កន្ទុយវែង។

**ទីជម្រក**

ព្រៃរបោះស្ងួត ព្រៃពាក់គណ្តាលស្រោង ព្រៃធម្មជាតិប្របមាត់ស្ទឹង ព្រៃកោងកាងនិងតំបន់កសិកម្ម។

**ការគំរាមកំហែង**

ការជួញដូរខុសច្បាប់ (ទិញលក់ធ្វើជាសត្វចិញ្ចឹមនិងបម្រើឱ្យសកម្មភាពលែងសត្វយកបុណ្យកុសល) និងការបាត់បង់ទីជម្រក។

**របាយរស់នៅ**

ប្រទេសកម្ពុជា អាហ្គានីស្ថាន ប៊ូតាន់ បង់ក្លាដែស ឥណ្ឌា លាវ ភូមា នេប៉ាល់ ប៉ាគីស្ថាន ស្រីលង្កា ថៃឡងដ៍និងវៀតណាម។

**របបអាហារ**

គ្រាប់ឈើព្រៃនិងគ្រាប់ឈើដំណាំកសិកម្ម ផ្កាព្រៃ ផ្កាក្រពុំ ទឹកដមផ្កា គ្រាប់ធញ្ញជាតិ ផ្លែឈើនិងបន្លែ។

NE DD LC LEAST CONCERN NT VU EN CR EW EX

# ចាបចង្ក្រង់

## Scaly-breasted Munia

## *Lonchura punctulata*



**រូបរាង**

ចំពុះកន្ទុបហើយក្រាស់ពណ៌ខ្មៅស្រអាប់ ខ្នងពណ៌ត្នោត ក្បាលពណ៌ត្នោតចាស់។ ផ្នែកខាងក្រោម (ទ្រូង ពោះនិងចំហៀងពោះ) ពណ៌សហើយមានក្រឡាអង្កន់ៗរាងដូចជាស្រកាត្រី។

**ទីជម្រក**

វាលស្មៅ សួនច្បារនិងវាលស្រែ តំបន់កសិកម្ម។

**ការគំរាមកំហែង**

ការជួញដូរធ្វើជាសត្វចិញ្ចឹមនិងការបាត់បង់ទីជម្រក។

**របបអាហារ**

គ្រាប់ឈើ ផ្លែឈើតូចៗនិងសត្វល្អិត។

**របាយរស់នៅ**

មានដើមកំណើតនៅតំបន់អាស៊ីអាគ្នេយ៍និងនៅប្រទេសឥណ្ឌា។ មានការនាំយកទៅតំបន់ផ្សេងៗយ៉ាងច្រើន រាយប៉ាយស្ទើរពាសពេញពិភពលោក។

NE DD LC LEAST CONCERN NT VU EN CR EW EX

# ត្រចៀកកាំ

**Barn Swallow**

***Hirundo rustica***



**ភិនភាគ**

ផ្នែកខ្នងពណ៌ខៀវរលោងហើយផ្នែកខាងក្រោម (ទ្រូង) មានលំដាប់ពណ៌ឆ្លាស់គ្នាចាប់ពីពណ៌ត្នោតលាយទឹកក្រូចភ្លឺ ទៅពណ៌ស។ ថ្ងាសនិងបំពង់កមានពណ៌ឈាមជ្រូក កន្ទុយផែកជ្រៅ។

**ទីជម្រក**

វាលលំហ ជាពិសេសតាមវាលស្រែធំៗនិងតំបន់ដីសើម មានភាពស៊ាំជាមួយនឹងការរស់នៅជុំវិញលំនៅដ្ឋានរបស់មនុស្ស។

**ការគំរាមកំហែង**

ការធ្វើកសិកម្មតាមបែបប្រពលវប្បកម្មនិងការជួញដូរខុសច្បាប់ (ការលែងសត្វយកបុណ្យកុសល)។

**របាយរស់នៅ**

ជាប្រភេទត្រចៀកកាំដែលរស់នៅស្ទើរតែពាសពេញសកលលោក មានវត្តមាននៅគ្រប់ទ្វីបទាំងអស់លើកលែងតែទ្វីបអង់តាកទិក។

**របបអាហារ**

សត្វល្អិតអាចហើរបាន: រុយ កន្លង់ ឃ្មុំ កណ្តូប មូសនិងកន្ធំរុយ។

# សារិកាកែវវង

NE DD LC LEAST CONCERN NT VU EN CR EW EX

## Common Hill Myna
## *Gracula religiosa*



ភិនភាគ

ខ្លួនពណ៌ខ្មៅរលោង មានខ្នែងក្បាលពណ៌លឿងខ្ចី ហើយមានចំពុះពណ៌ទឹកក្រូច។ ស្លាបពណ៌ខ្មៅ ដោយមានបណ្តុំរោមពណ៌សនៅលើស្លាប ដែលអាចមើលឃើញច្បាស់នៅពេលវាហើរ។ សារិកាកែវវងមានភាពវាងវៃអាចធ្វើត្រាប់តាមសំលេងនិងការនិយាយរបស់មនុស្សបាន។

ទីជម្រក

ព្រៃរងទឹកភ្លៀងតំបន់ត្រូពិច ព្រៃពាក់កណ្ដាលស្រោងតំបន់ទំនាប តំបន់ខ្ពង់រាបនិងតំបន់ភ្នំ។

ការគំរាមកំហែង

ការបាត់បង់ទីជម្រកនិងការជួញដូរធ្វើជាសត្វចិញ្ចឹមនៅទូទាំងទ្វីបអាស៊ី។

របៀបរស់នៅ

ប្រទេសកម្ពុជា ប៊ូតាន់ ព្រុយនេ ចិន ឥណ្ឌា ឥណ្ឌូនេស៊ី លាវ ម៉ាឡេស៊ី ភូមា នេប៉ាល់ ហ្វីលីពីន សិង្ហបុរី ថៃឡង់និងវៀតណាម។

របបអាហារ

សារិកាកែវវងជាពួកផល្លាសី ប៉ុន្តែវាក៏យកទឹកដមផ្កា បាណកសត្វ (សត្វល្អិត) ពងសត្វនិងសត្វល្អូនតូចៗ។

NE DD LC NT VU EN **CR** CRITICALLY ENDANGERED EW EX

# ត្រយងយក្ស ឬឱលើក

## Giant Ibis

## *Thaumatibis gigantea*



**ភិនភាគ**

ជាសត្វត្រយងដែលមានមាឌធំ រោមពណ៌ប្រផេះត្នោតលាយបៃតងរលោង ស្លាបពណ៌ប្រផេះ ហើយមានរោមចុងស្លាបពណ៌ខ្មៅ។ ក្បាលនិងកមួយផ្នែកត្រងោល (គ្មានរោម) ដោយមានឆ្នូតអង្កន់ៗពណ៌ខ្មៅ ចំពុះវែងកោងខុបពណ៌ព្រលែត ជើងវែងពណ៌ក្រហមនិងមានភ្នែកពណ៌ក្រហមចាស់។

**ទីជម្រក**

វាច្រើនរស់នៅតាមព្រៃរបោះដែលមានត្រពាំងច្រើន។ ព្រៃតាមតំបន់ដីសើម បឹងនិងទន្លេ។

**ការគំរាមកំហែង**

ការបរិវត្តន៍ទីជម្រក ការកាប់បំផ្លាញព្រៃឈើ ការរំខានផ្សេងៗពីមនុស្ស ការបរបាញ់និងការប្រមូលពង។

**របាយរស់នៅ**

កម្ពុជា លាវនិងវៀតណាម។ ច្រើនមានវត្តមាននៅភាគខាងជើងនិងខាងកើតប្រទេសកម្ពុជា។

**របបអាហារ**

សត្វឥតឆ្អឹងកង សត្វវន្តជាតិ (ក្តាម) សិប្បីជាតិ (ខ្យង) អន្ទង់ ថលជលិក តូចៗនិងឧរង្គសត្វ (ល្មូន)។

NE | DD | LC | NT | VU | EN | CR CRITICALLY ENDANGERED | EW | EX

# ត្រយងចង្កំកស

## White-shouldered Ibis
## *Pseudibis davisoni*



**ភិនភាគ**

ខ្លួនពណ៌ត្នោតចាស់ ហើយមានគល់ស្លាបផ្នែកខាងលើពណ៌បៃតងលាយខៀវរលោង។ ចង្កំក ឬ ប្រទ្បៀកពណ៌ស ក្បាលត្រងោល (គ្មានរោម) ពណ៌ខ្មៅ។ មានបណ្តុំរោមពណ៌សនៅលើស្មា (គល់ស្លាប) ដែលអាចមើលឃើញច្បាស់ពេលវាហើរ។ ជើងវែងពណ៌ក្រហមស្រអាប់ និងភ្នែកពណ៌ក្រហម។

**ទីជម្រក**

វាច្រើនរស់នៅតាមព្រៃរបោះដែលមានត្រពាំងច្រើន។ ព្រៃតាមតំបន់ដីសើម បឹងនិងទន្លេ។

**ការគំរាមកំហែង**

ការបាត់បង់ទីជម្រក ការកាប់បំផ្លាញព្រៃឈើ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងកសិកម្មនិងការបរបាញ់។

**របាយរស់នៅ**

កម្ពុជា លាវនិងវៀតណាម។ ច្រើនមានវត្តមាននៅភាគខាងជើងនិងខាងកើតប្រទេសកម្ពុជា។

**របបអាហារ**

សត្វឥតឆ្អឹងកង សត្វវន្តជាតិ (ខ្យង) សិប្បីជាតិ (ក្តាម) អន្ទង់ ថលជលិកតូចៗនិងឧរង្គសត្វ (ល្មូន)។

NE DD LC NT VU EN CR CRITICALLY ENDANGERED EW EX

# ត្មាតត្លើខ

## Red-headed Vulture

## *Sarcogyps calvus*



**ភិនភាគ**

ដងខ្លួនពណ៌ខ្មៅរលោង រោមកផ្នែកខាងមុខពណ៌ស និងមានមានបណ្តុំរោមពណ៌សនៅលើគល់ភ្លៅ។ ក្បាលពណ៌ក្រហម ហើយមានស្បែកយារធ្លាក់រយ៉ានៅសងខាងក។ កជើងនិងម្រាមជើងក៏ពណ៌ក្រហមដែរ។ ឈ្មោលមានភ្នែកពណ៌លឿង ប៉ុន្តែញីវិញមានភ្នែកពណ៌ត្នោតចាស់។

**ទីជម្រក**

វាលលម្ហតំបន់ដាច់ស្រយាល តំបន់ភ្នំនិងព្រៃរបោះស្ងួត។ ជាទូទៅវារស់នៅឆ្ងាយពីកន្លែងមនុស្សរស់នៅ។

**ការគំរាមកំហែង**

ការថយចុះចំនួនសត្វក្រចកជើងជំពាម ការបរិវត្តន៍ទីជម្រក ជាតិពុល (ការបំពុលសត្វ) ការកាប់បំផ្លាញដើមឈើដែលសត្វធ្វើសំបុក ការសម្លាប់ដោយផ្ទាល់ ការប្រើប្រាស់ថ្នាំ NSAID មានដូចជាឌីក្លូហ្វេណាក់ (diclofenac) និងកេតូប្រូហ្វិន (Ketoprofen) ដើម្បីព្យាបាលសត្វស្រុក។

**រប៉ាយរស់នៅ**

ប្រទេសកម្ពុជា បង់ក្លាដែស ចិន លាវ ភូមា នេប៉ាល់ និងវៀតណាម។

**របបអាហារ**

សាច់សាកសពស្អុយ: សាកសពសត្វក្រចកជើងជំពាម បក្សីសត្វ ល្មូន និងត្រី។

NE DD LC NT VU EN CR CRITICALLY ENDANGERED EW EX

# ត្មាតផេះ

## White-rumped Vulture
## *Gyps bengalensis*



**ភិនភាគ**

ដងខ្លួនពណ៌ខ្មៅរលោង។ រោមកពណ៌ស រោមកញ្ចុំចុងខ្នងនិងផ្នែកខាងក្រោមពណ៌ស។ ក្បាលនិងកត្រងោល (គ្មានរោម) ពណ៌ប្រផេះលាយត្នោត ហើយមានចំពុះពណ៌ខ្មៅ។

**ទីជម្រក**

វាលលម្អតំបន់ដាច់ស្រយាលនិងព្រៃរបោះស្ងួត។ វាក៏អាចរស់នៅក្បែរកន្លែងមនុស្សរស់នៅផងដែរ។

**ការគំរាមកំហែង**

ការខ្វះខាតចំណី ការបរិវត្តន៍ទីជម្រក ជាតិពុល (ការបំពុលសត្វ) ការកាប់បំផ្លាញដើមឈើដែលសត្វធ្វើសំបុក ការសម្លាប់ដោយផ្ទាល់ ការប្រើប្រាស់ថ្នាំ NSAID មានដូចជាឌីក្លូហ្វេណាក់(diclofenac)និងកេតូប្រូហ្វិន (Ketoprofen) ដើម្បីព្យាបាលសត្វស្រុក។

**របាយរស់នៅ**

ប្រទេសកម្ពុជា អាហ្គានីស្ថាន បង់ក្លាដែស ឥណ្ឌា ភូមា នេប៉ាល់និងប៉ាគីស្ថាន។

**របបអាហារ**

សាច់សាកសព: សាកសពស្អុយនិងសាកសពស្រស់ៗ។

# ត្មាតត្នោត

## Slender-billed Vulture
*Gyps tenuirostris*

NE DD LC NT VU EN ‹ CR › EW EX

CRITICALLY ENDANGERED

RED LIST



**ភិនភាគ**

ដងខ្លួននិងស្លាបរាងព្រលែត ពណ៌ខ្សាច់លាយត្នោត។ ក្បាលត្រងោលកវែង ព្រមទាំងចំពុះវែងស្រួចរបស់វាពណ៌ខ្មៅ។ មានរោមកតិចហើយខ្លីពណ៌ស។ រោមកញ្ចុំចុងខ្នងនិងផ្នែកខាងក្រោមពណ៌ស។ ស្លាបកែវរបស់វាពណ៌ខ្មៅនៅចំកណ្ដាល ទាំងផ្នែកខាងលើនិងផ្នែកខាងក្រោមស្លាប។

**ទីជម្រក**

វាលលម្ហរតំបន់ដាច់ស្រយាលនិងតំបន់ព្រៃលម្ហ។ ជាទូទៅវារស់នៅឆ្ងាយពីកន្លែងមនុស្សរស់នៅ។

**ការគំរាមកំហែង**

ការថយចុះចំនួនសត្វក្រចកជើងជំពាម ការបរិវត្តន៍ទីជម្រក ជាតិពុល (ការបំពុលសត្វ) ការកាប់បំផ្លាញដើមឈើដែលសត្វធ្វើសំបុក ការសម្លាប់ដោយផ្ទាល់ ការប្រើប្រាស់ថ្នាំ NSAID មានដូចជាឌីក្លូហ្វេណាក់ (diclofenac)និងកេតូប្រូហ្វិន(Ketoprofen) ដើម្បីព្យាបាលសត្វស្រុក។

**រប៉ាយរស់នៅ**

ប្រទេសកម្ពុជា បង់ក្លាដែស ឥណ្ឌា ភូមា នេប៉ាល់ និងលាវ។

**របបអាហារ**

សាច់សាកសព: សាកសពស្អុយនិងសាកសពស្រស់ៗ។

NE DD LC NT VU VULNERABLE EN CR EW EX

# ក្រៀល

## Sarus Crane

## *Grus antigone*



**ភិនភាគ**

ដងខ្លួនសម្បុរប្រផេះព្រលែត ជើងវែងពណ៌ក្រហមព្រលែត។ ក្បាលនិងកផ្នែកខាងលើត្រងោលពណ៌ក្រហម។

**ទីជម្រក**

វាលស្មៅលម្ហតំបន់ដីសើមនិងស្ងួត តំបន់កសិកម្ម តំបន់វាលភក់ បឹងនិងព្រៃរបោះដែលមានត្រពាំងច្រើន។

**ការគំរាមកំហែង**

ការបាត់បង់ទីជម្រកនិងការបំផ្លិចបំផ្លាញទីជម្រក ការរំខានផ្សេងៗពីមនុស្ស ការជួញដូរសត្វពេញវ័យ កូនសត្វនិងពងសត្វ។

**រប៉ាយរស់នៅ**

ប្រទេសកម្ពុជា អូស្ត្រាលី ឥណ្ឌា លាវ ភូមា នេប៉ាល់ ប៉ាគីស្ថាននិងវៀតណាម។

**របបអាហារ**

សព្វាសីៈ ឫសនិងមើមរុក្ខជាតិ សត្វឥតឆ្អឹងកងនិងថលជលិក (សន្ទានសត្វកង្កែប)។

NE DD LC NT VU EN **CR** EW EX
CRITICALLY ENDANGERED

# ខ្សឹប ឬទ្រមាក់អណ្ដើក

## Bengal Florican
## *Houbaropsis bengalensis*



**រប៉ាយរស់នៅ**

ប្រទេសកម្ពុជា ឥណ្ឌានិងនេប៉ាល់

**ភិនភាគ**

ឈ្មោលសម្បុរខ្មៅដោយមានខ្នងពណ៌ត្នោតពព្រុស ហើយស្លាបពណ៌ស ស្ទើរតែទាំងអស់។ ញីមានសម្បុរត្រសក់-ត្នោត ដែលមានស្នាមអុចៗពណ៌ខ្មៅនៅផ្នែកខាងលើ ចុងប៉ុចក្បាលពណ៌ខ្មៅដោយមានឆ្នូតចំកណ្ដាលក្បាលពណ៌ត្នោត។ កនិងទ្រូងផ្នែកខាងលើពណ៌ត្នោត។

**ទីជម្រក**

វាលស្មៅធម្មជាតិ វាលស្មៅដុះឡើងវិញនិងវាលស្រែតាមតំបន់លិចទឹកតាមរដូវកាល( តំបន់ជុំវិញបឹងទន្លេសាប )។
ក្នុងរដូវវស្សា វារស់នៅតាមតំបន់ព្រៃរបោះរេចរឹល។

**ការគំរាមកំហែង**

ការបាត់បង់ ការបំផ្លាញនិងការបរិវត្តន៍ទីជម្រក។ ការរំខានផ្សេងៗទៀតមានដូចជា ខ្សែអគ្គិសនី ឆ្កែប្រមាញ់និងការបរបាញ់។

**របបអាហារ**

សព្វាសីៈ គ្រាប់រុក្ខជាតិ ធញ្ញជាតិ បណ្ដូលស្មៅខ្ចីៗនិងបាណកសត្វ (កណ្ដូប ចង្រឹត)។




# រំពេទន្លេ

## River Tern

## *Sterna aurantia*




**ភិនភាគ**

ខ្លួនពណ៌ប្រផេះ-ស ស្លាបពណ៌ប្រផេះព្រលែត។ កន្ទុយឆែក ហើយមានស្លាបកន្ទុយខាងក្រៅរាងវែងៗដូចគេចងលម្អ។ ចំពុះពណ៌លឿង ជើងពណ៌ក្រហម ហើយបន្ទូលក្បាលនិងភ្នែកពណ៌ខ្មៅ។ បន្ទូលក្បាលពណ៌ខ្មៅក្នុងរដូវពងកូន តែមានឆ្នូតពណ៌ប្រផេះចាស់ក្នុងរដូវមិនបន្តពូជ។

**ទីជម្រក**

ទន្លេធំៗនិងបឹងទឹកសាប។
វាក៏មានវត្តមានដោយកម្រ តាមតំបន់ពាមជាប់មាត់សមុទ្រ។

**ការគំរាមកំហែង**

ទឹកជំនន់ ការប្រមូលពងនិងកូន ការខ្វះខាតចំណីនិងការរំខានផ្សេងៗ។

**របាយរស់នៅ**

ប្រទេសកម្ពុជា ប៉ាគីស្ថាន ឥណ្ឌា បង់ក្លាដែស ភូមា ថៃឡង់ដ៍ ចិន នេប៉ាល់ ប៊ូតាន់ លាវនិងវៀតណាម។

**របបអាហារ**

ចំណីចម្បងរបស់វាគឺ ត្រី សត្វវន្តជាតិ (ក្តាម) សិប្បីជាតិ (ខ្យង) កង្កែប កូនក្អុកនិងសត្វល្អិតរស់នៅក្នុងទឹកជាច្រើនទៀត។

NE DD LC NT VU EN ENDANGERED CR EW EX

# បបែលទឹកសាប

## Giant Freshwater Ray
## *Urogymnus polylepis*



**ភិនភាគ**

ខ្លួនពណ៌ប្រផេះត្នោត មាឌធំ (រហូតដល់ទៅ ២៤០ ស.ម) ហើយមានរាងមូលសំប៉ែតដូចថាស កន្ទុយវែងដូចរំពាត់ខ្សែតី។ វាមានទំពក់នៅគល់កន្ទុយប្រវែងប្រមាណ ៣៨ ស.ម។ ប្រវែងខ្លួនសរុបទាំងកន្ទុយផង ប្រមាណ ៥០០ ស.ម។

**ទីជម្រក**

ទន្លេធំៗហើយជ្រៅ ហើយមានភក់ ឬ ខ្សាច់នៅបាតទន្លេនិងតាមតំបន់ពាមជាប់មាត់សមុទ្រ។

**ការគំរាមកំហែង**

ការចាប់ច្រើនហួសប្រមាណដើម្បីធ្វើអាជីវកម្មជលវប្បដ្ឋាន កីឡាស្ទូចត្រីកំសាន្ត ការបំផ្លាញជម្រករបស់វាតាមតំបន់ទន្លេនិងជាតិពុល។

**របាយរស់នៅ**

ប្រទេសកម្ពុជា ឥណ្ឌា ឥណ្ឌូនេស៊ី លាវ ម៉ាឡេស៊ី ថៃឡង់ដ៍និងវៀតណាម។

**របបអាហារ**

មំសាសីៈ ស៊ីពួកសត្វឥតឆ្អឹងកង សត្វវន្តជាតិ (ក្តាម) សិប្បីជាតិ (ខ្យង) និងមច្ឆជាតិ។

NE DD LC NT VU EN **CR** CRITICALLY ENDANGERED EW EX

# ត្រីត្រសក់

## Seven-striped Barb
## *Probarbus jullieni*



**ភិនភាគ**

ប្រវែងដងខ្លួនខ្លីជាង ១៥ ស.ម។ មានឆ្នូតបណ្ដោយខ្លួន៥ ចន្លោះរវាងព្រុយខ្នងនិងចុងស្រកី។ មានមាឌធំ មាត់តូច ហើយមានស្រកា ៤ជួរ ចន្លោះពីចុងស្រកី ទៅព្រុយកន្ទុយ។

**ទីជម្រក**

ទន្លេធំៗដែលមានខ្សាច់ ឬ គ្រួសស្ថិតនៅបាតក្រោមនិងមានសិប្បីជាតិច្រើន (ខ្យង ខ្ចៅ គ្រំ លៀស)។

**ការគំរាមកំហែង**

ការនេសាទច្រើនហួសប្រមាណ ការបំផ្លាញទីជម្រកនិងទំនប់វារីអគ្គីសនីធំៗ។

**របបអាហារ**

សព្វាសីៈ ចំណីរបស់វាគឺ ប្លង់តុង រុក្ខជាតិដុះតាមទឹក ផ្លែឈើ សត្វឥតឆ្អឹងកង សិប្បីជាតិ (ខ្យង ខ្ចៅ គ្រំ លៀស) កំពឹសនិងក្ដាម។

**ប៉ោយរស់នៅ**

ប្រទេសកម្ពុជា លាវ ម៉ាឡេស៊ី ថៃឡង់ និងវៀតណាម។

# ត្រីគល់រាំង ឬ ត្រីក្បាលឡាន

## Giant Barb

## *Catlocarpio siamensis*

NE DD LC NT VU EN **CR** CRITICALLY ENDANGERED EW EX



| | |
|---|---|
| ភិនភាគ | ភ្នែកផតចូលក្នុងស្ទើរតែពាក់កណ្ដាលនៃក្បាលមួយចំហៀង។ ព្រុយខ្នងគ្មានឆ្អឹង ហើយអត់មានពុកមាត់ទេ។ ប្រវែងខ្លួនប្រមាណ ៣០០ ស.ម (ប៉ុន្តែវាកម្រណាស់) ភាគច្រើនមានវែង វែងជាង ២០០ ស.ម។ |
| ទីជម្រក | ទន្លេធំៗនិងតំបន់លិចទឹកតាមដងទន្លេមេគង្គ (អាងទន្លេមេគង្គនិងទន្លេចៅផ្រាយ៉ា)។ |
| ការគំរាមកំហែង | ការចាប់ច្រើនហួសប្រមាណ ការបាត់បង់ទីជម្រកនិងការបែកខ្ញែកទីជម្រក ទំនប់វារីអគ្គិសនីនិងជាតិពុល។ |
| របាយរស់នៅ | ប្រទេសកម្ពុជា លាវ ថៃឡង់និងវៀតណាម។ |
| របបអាហារ | សព្វាសីៈ ស៊ីក្តាម កំពឹស រុក្ខជាតិដុះតាមទឹក(សារាយ) ប្លង់តុង និងផ្លែរុក្ខជាតិដែលដុះតាមព្រៃលិចទឹក។ |

NE DD LC NT VU EN CR CRITICALLY ENDANGERED EW EX

# ត្រីរាជ

## Mekong Giant Catfish
*Pangasianodon gigas*



**ភិនភាគ** ខ្លួនពណ៌ប្រផេះ គ្មានឆ្នូតទេ។ ភ្នែកទាំងគូរបស់វាមានកម្រិតទាប នៅក្រោមរង្វះមាត់ ត្រីរាជធំពេញវ័យគ្មានធ្មេញ។ ស្ទើរតែគ្មានពុកមាត់។ ទម្ងន់រហូតដល់ ៣៥០ គ.ក។

**ទីជម្រក** ទន្លេមេគង្គ។

**ការគំរាមកំហែង** ការនេសាទច្រើនហួសប្រមាណ ការបាតបង់ទីជម្រកនិងការបំផ្លិចបំផ្លាញទីជម្រក។ ជាតិពុលនិងការយកហ្សែនបង្កាត់ពូជជាមួយប្រភេទផ្សេងៗទៀតតាមរយៈការធ្វើសន្និធិ។

**របបអាហារ** តិណាសីៈ ស៊ីរុក្ខជាតិនិងរុក្ខជាតិដុះលើទឹក (សារាយ)។

**រប៉ាយរស់នៅ** ប្រទេសកម្ពុជា លាវ ថៃឡង់និងវៀតណាម។

# ឧបសម្ព័ន្ធ៖ ឯកសារយោង


Content of Environmental Life Skills for Teacher Training Centers, the Ministry of Education, Youth and Sport (Kingdom of Cambodia)

Cambodian Law on Forestry in 2002 (Chapter 10: Articles 48- 50)

Cambodian Law on Fishery in 2006 (Chapter 5: Articles 20- 23)

Das, I. 2008. Pelochelys cantorii Gray 1864 – Asian giant softshell turtle. In: Rhodin, A.G.J., Pritchard, P.C.H., van Dijk, P.P., Saumure, R.A., Buhlmann, K.A., and Iverson, J.B. (Eds.). Conservation Biology of Freshwater Turtles and Tortoises: A Compilation Project of the IUCN/SSC Tortoise and Freshwater Turtle Specialist Group. Chelonian Research Monographs No. 5, pp. 011.1-011.6,

Man Soriyonn, Suon Phalla, Sin Polin and Joe Walston- A Guide to the Mammals of Cambodia (WCS- Cambodia Programme and MAFF- Ministry of Agriculture, Forestry & Fisheries)

Moll, E. et al. "Batagur affinis (Cantor 1847) – Southern River Terrapin, Tuntong." (2015)

Mahood et al. 2019. A systematic expert-based assessment of progress and priorities for conservation of the Bengal Florican Houbaropsis bengalensis

Rainboth, W.J., 1996. Fishes of the Cambodian Mekong. FAO species identification field guide for fishery purposes. FAO, Rome, 265 p.

Rhodin et al. 2018. Global Conservation Status of Turtles and Tortoises (Order Testudines). Chelonian Conservation and Biology 17(2): 135-161

# ឧប្បសម្ព័ន្ធ៖ ឯកសារយោង


Robson 2005. Birds of South-East Asia: Concise Edition

River of Giants, Giant fish of the Mekong

Stenkat J. et al. 2019. Wildlife and Environment Protection and Conservation, A guide book for Buddhist monks in Cambodia. Angkor Centre for Conservation of Biodiversity (ACCB)

Tan Setha and Poole, C.M. (2003)- A Field Guide to the Birds of Cambodia (WCS-Cambodia Programme)

Vassilieva et al. 2016. A photographic Field Guide to the Amphibians and Reptiles of the Lowland Monsoon Forests of Southern Vietnam

www.pangolinsg.org/pangolins/sunda-pangolin/

www.iucnredlist.org

www.animaldiversity.org

https://www.iucn.org/regions/asia/our-work/coastal-and-marine-ecosystems

http://chm.aseanbiodiversity.org/index.php?option=com_wrapper&view=wrapper&Itemid=307

# ឧបសម្ព័ន្ធ៖ សិទ្ធលើរូបភាព

គំនូរនៅក្រមមុខ ក្របក្រោយ និងនៅទំព័រ ៩ គូរដោយកញ្ញា ម៉ារៀ ចារ៉ា ផារ៉ូលីន (Maria Chiara Parolin)។
រូបភាពស្ទើរតែទាំងអស់ រក្សាសិទ្ធិដោយ ACCB លើកលែងតែរូបភាពមួយចំនួនដែលមានបញ្ជាក់ឈ្មោះអ្នកថតរូបដូចខាងក្រោម៖

| | | |
|---|---|---|
| ទំព័រ | ២ | ពីឆ្វេងទៅស្តាំ:<br>ACCB/ Michael Meyerhoff<br>ACCB/ Mark Dainty<br>ACCB/ ជិម សុភាព<br>ACCB/ Philipp Wagner |
| ទំព័រ | ៤ | clipartmax.com |
| ទំព័រ | ៦ | clipartmax.com |
| ទំព័រ | ៨ | clipartmax.com |
| ទំព័រ | ១០ | icem |
| ទំព័រ | ១១ | OSMOSE |
| ទំព័រ | ១២ | Buffalo Trails |
| ទំព័រ | ១៣ | ឆ្វេង: ACCB/ ជិម សុភាព<br>កណ្តាលនិងស្តាំ:ACCB/ Stephanie Jessen |
| ទំព័រ | ១៤ | យ៉ុន តូនី |
| ទំព័រ | ១៥ | ACCB/ Michael Meyerhoff |
| ទំព័រ | ១៩ | ACCB/ ជិម សុភាព |
| ទំព័រ | ២០ | ACCB/ Michael Meyerhoff |
| ទំព័រ | ២១ | ACCB/ WCS |
| ទំព័រ | ២២ | មិនដឹងប្រភព |
| ទំព័រ | ២៣ | ACCB/ ជិម សុភាព |
| ទំព័រ | ២៥ | លើ: WCS/ សោម ស៊ីថា<br>ក្រោម: ACCB/ Daniel Roper-Jones |
| ទំព័រ | ២៦ | សៀវភៅសម្រែកព្រៃឈើ |
| ទំព័រ | ២៧ | ACCB/ ចៅ ឡេងថុល |
| ទំព័រ | ២៨ | Traffic SEA |
| ទំព័រ | ៣១ | ក្រោម: ACCB/ ជិម សុភាព |
| ទំព័រ | ៣២ | ឆ្វេង: Alison Copeland (inaturalists)<br>កណ្តាល និងស្តាំ: Buffalo Trails |
| ទំព័រ | ៣៤ | Eric Guerin |
| ទំព័រ | ៣៥ | សម្ព័ន្ធមិត្តសត្វព្រៃ |
| ទំព័រ | ៣៧ | M3MFoundation |
| ទំព័រ | ៤៦ | WWF-Cambodia |
| ទំព័រ | ៤៨ | ACCB/ Pau Puigcerver |
| ទំព័រ | ៥០ | Wayne Fidler (inaturalists) |
| ទំព័រ | ៥១ | Free the Bears |
| ទំព័រ | ៥៤ | MCF/ ប៊ុន សាលួត |
| ទំព័រ | ៥៧ | WWF-Cambodia |
| ទំព័រ | ៥៨ | ACCB/ Pau Puigcerver |
| ទំព័រ | ៥៩ | Jonas Livet (www.leszoosdanslemondecom) |

# ឧបសម្ព័ន្ធ៖ សិទ្ធលើរូបភាព

ទំព័រ ៦០ WWF-Cambodia
ទំព័រ ៦១ ACCB/ Stephanie Jessen
ទំព័រ ៦២ WWF-Cambodia
ទំព័រ ៦៣ WWF-Cambodia
ទំព័រ ៦៩ ឈ្មោល: WCS/ Mengey Eng
ញី: WCS/ សោម ស៊ីថា
ទំព័រ ៧០ ACCB/ Pau Puigcerver
ទំព័រ ៧២ ACCB/ Pau Puigcerver
ទំព័រ ៧៣ Nksnakes ( inaturalists )
ទំព័រ ៧៤ Anukma ( inaturalists )
ទំព័រ ៧៥ ACCB/ Christel Griffioen
ទំព័រ ៧៦ ACCB/ Stephanie Jessen
ទំព័រ ៧៧ ACCB/ Pau Puigcerver
ទំព័រ ៧៩ ឆ្វេង: ACCB/ Christel Griffioen
ស្តាំ: ACCB/ Stephanie Jessen
ទំព័រ ៨១ ACCB/ ថៅ ឡេងថុល
ទំព័រ ៨២ Joel Sartore/ National Geographic Photo Ark
ទំព័រ ៨៣ Sudharshan Kuselan ( inaturalists )
ទំព័រ ៨៤ ACCB/ Pau Puigcerver
ទំព័រ ៨៥ ACCB/ Pau Puigcerver
ទំព័រ ៨៦ ACCB/ Pau Puigcerver
ទំព័រ ៨៧ Matt K ( inaturalists )
ទំព័រ ៨៨ ACCB/ Stephanie Jessen
ទំព័រ ៨៩ ACCB/ Petter Yen
ទំព័រ ៩០ ACCB/ Michael Meyerhoff
ទំព័រ ៩១ ACCB/ Pau Puigcerver
ទំព័រ ៩២ ACCB/ Oliver Gray Read
ទំព័រ ៩៣ ACCB/ Oliver Gray Read
ទំព័រ ៩៤ ACCB/ ជិម សុភាព
ទំព័រ ៩៥ ACCB/ Pau Puigcerver
ទំព័រ ៩៦ ឡូ គឹមសាន/ WWF-Cambodia
ទំព័រ ៩៧ G M MASUM BILLAH ( inaturalists )
ទំព័រ ៩៨ Karim Haddad ( inaturalists )
ទំព័រ ៩៩ ePond.eu
ទំព័រ ១០០ KKPCW ( inaturalists )

អង្គការ WWF បម្រើការងារនៅជាង ១០០ប្រទេស ដើម្បីការកសាងអនាគតសម្រាប់ការរស់នៅប្រកបដោយភាពសុខដុមរមនារវាងមនុស្សជាមួយនឹងធម្មជាតិ។ ដោយសារសុខុមាលភាពរបស់មនុស្ស សត្វព្រៃនិងបរិស្ថានធម្មជាតិ ត្រូវបានផ្សារភ្ជាប់គ្នាយ៉ាងជិតស្និទ្ធ ទើប WWF អនុវត្តន៍តាមយុទ្ធសាស្ត្រសមាហរណកម្មដើម្បីឆ្ពោះទៅសម្រេចគោលដៅការងាររបស់ខ្លួន។ WWF ខិតខំថែរក្សា ការពារធម្មជាតិក្នុងពិភពលោក ជួយដល់ប្រជាជនឱ្យរស់នៅប្រកបដោយនិរន្តរភាពនិងចាត់វិធានការដើម្បីប្រយុទ្ធប្រឆាំងជាមួយនឹងការប្រែប្រួលអាកាសធាតុ។

កម្មវិធី ជំនឿនិងគុណតម្លៃ របស់ WWF ដែលបានឧបត្ថម្ភសៀវភៅមគ្គុទ្ទេសក៍នេះឡើងដើម្បីកៀរគរ ឱ្យមានការចូលរួមពីថ្នាក់ដឹកនាំមូលដ្ឋាននិងសហគមន៍ តាមបែបបទជំនឿអរូបិយ សាសនានិងវប្បធម៌ ព្រមទាំងគុណប្រយោជន៍របស់ពួកគេ។

មជ្ឈមណ្ឌលអង្គរសម្រាប់ការអភិរក្សជីវៈចម្រុះ (ACCB) ត្រូវបានបង្កើតឡើងនិងប្រតិបត្តិការដោយសួនសត្វអាល់វិតធឿស្សូម៊ីនស្ទឿ Allwetterzoo Münster។ ACCB គឺជាមជ្ឈមណ្ឌលអភិរក្សសត្វព្រៃមុនដំបូងគេបង្អស់មួយនៅប្រទេសកម្ពុជា ដែលមានទីតាំងនៅជើងភ្នំក្បាលស្ពាន ចម្ងាយប្រហែលជា ៥០គីឡូម៉ែត្រ ខាងជើងតំបន់អង្គរដែលជាបេតិកភណ្ឌពិភពលោកដ៏ល្បីល្បាញមួយ ទទួលស្គាល់ដោយអង្គការយូណេស្កូ។ ជារៀងរាល់ឆ្នាំ សត្វព្រៃរាប់រយក្បាលត្រូវបានស្តារនីតិសម្បទា ហើយលែងត្រឡប់ទៅក្នុងព្រៃធម្មជាតិវិញ (ប្រសិនបើអាច)។ លើសពីនេះទៀត ACCB បានអនុវត្តសកម្មភាពអប់រំបរិស្ថានដើម្បីលើកកម្ពស់ការយល់ដឹងអំពីការគំរាមកំហែងនានាដែលប៉ះពាល់ដល់ប្រភេទសត្វព្រៃដែលរងគ្រោះជិតផុតពូជនៅប្រទេសកម្ពុជា។ សៀវភៅ **បរិការណ៍នៃការអភិរក្សនៅប្រទេសកម្ពុជានិងបញ្ហាប្រឈម** នេះត្រូវបានរៀបចំឡើងដើម្បីគាំទ្រ ពង្រឹងសមត្ថភាពដល់ព្រះសង្ឃពុទ្ធសាសនាដែលបានចូលរួមយ៉ាងសកម្មក្នុងកិច្ចការពារនិងអភិរក្សសត្វព្រៃនៅប្រទេសកម្ពុជា។